ក. 306. ក

ឆ្នាំទី ១

**លេខ ៣**

# ទស្សនាវដ្តីចេញរាល់ខែ

ខែវិច្ឆិកា ឆ្នាំ ១៩៥៦

ក 306 ក

ឆ្នាំទី ១ លេខ ៣ ខែវិច្ឆិកា ១៩៥៦

# ទស្សនាវដ្ដី

## នៃសមាគមសាមគ្គីសិស្សចាស់នឹងមិត្តសិស្ស

## នៃអនុវិទ្យាល័យ នឹង វិទ្យាល័យស៊ីសុវត្ថិ

---

ទីសំណាក់ការ លេខ ១៣០ វិថី ប៉ាស្ទ័រ ភ្នំពេញ

# មាតិការឿង

ទំព័រ

ទំព័រអក្សរសាស្ត្រ (ដំណើរនៃការសិក្សានៅប្រទេសខ្មែរ) ........ ១

រឿងមុខងារផាការចាំបាច់ ........ ៨

ប្រវត្តិសាស្ត្រ ( ប្រវត្តិនៃសង្គមមនុស្ស ) ........ ១៣

បញ្ហាអនាម័យ ........ ២៤

កីឡា (អត្តពលកម្ម) ........ ៤១

កំណាព្យខ្មែរ ........ ៤៧

លទ្ធផលនៃការសិក្សា ........ ៤៩

សំនួរកំសាន្ត ........ ៥១

## តម្លៃជាវ

ក្នុងប្រទេស

| ១ ក្បាល | ៣ខែ | ៦ខែ | ១ ឆ្នាំ |
|---|---|---|---|
| ១០រ | ៣០រ | ៥០រ | ១០០រ |

ក្រៅប្រទេស

| ១ក្បាល | ៣ខែ | ៦ ខែ | ១ឆ្នាំ |
|---|---|---|---|
| ១៣រ | ៣៥រ | ៦០រ | ១២០រ |

*សូមផ្ញើអាណត្តិទៅលោក សុក-ក្នុល* លេខ ១៣០ វិថីប៉ាស្ទ័រ ភ្នំពេញ

# ទំព័រអក្សរសាស្ត្រ

## ដំណើរនៃការសិក្សា

សូមលោកអ្នកអ.នជ្រាបថា របស់អ្វីក៏ដោយដែលកើតមានក្នុងសង្គមនិមួយ ៗ តែងតែជាវត្ថុបញ្ចាំងនៃរបបសេដ្ឋកិច្ច របបសង្គមនិងរបបនយោបាយនៃសង្គមនោះទាំងអស់ ។ សង្គមជំនាន់សក្តិភូមិមានអង្គការមួយបែបសំរាប់សង្គមនោះទៅ សង្គមគហបតីដែលមានរបបគ្រប់គ្រងខុសពីសង្គមមុន ក៏មានអង្គការខុសពីអង្គការមុននោះដែរ ។ សង្គមមូលធនក៏មានអង្គការសំរាប់តែរបបរបស់គេទៅ ។ អង្គការដែលប្រែប្រួលយ៉ាងនេះសំរាប់តែការពារប្រយោជន៍នៃជន នៃវណ្ណៈណាដែលមានអំណាចក្នុងមួយគ្រា ៗ ។ សម័យដែលត្រកូលអភិជនកាន់អំណាច គេក៏បង្កើតស្ថាប័នសំរាប់តែលើកក្រុមរបស់គេទៅ ដល់ពួកគហបតីឈ្នះវិញក៏គេសម្រួលស្ថាប័នសង្គមឲ្យត្រូវនឹងប្រយោជន៍ពួកគេវិញ ។

ចំណែកខាងការសិក្សាក៏មានដំណើរដូច្នេះដែរ ។ ការសិក្សាប្រែប្រួលទៅតាមរបបសង្គមនិមួយ ៗ ដូចជាស្ថាប័នឯទៀត ៗ នៅស្រុកណាក៏ដោយ

ការសិក្សាត្រូវតែស្របនឹងរបបសេដ្ឋកិច្ចរបស់សង្គម នឹងរបបនយោបាយនៃស្រុកនោះ នៃពេលនោះ ។

ក្នុងសម័យសក្តិភូមិ សាលារៀនយកកំនាំតាមរបបសង្គមនោះទៅ ។ ពួកអភិជននៅប្រទេសអឺរ៉ុបជំនាន់សក្តិភូមិ គេមិនរៀនមើល រៀនសរសេរ រៀនលេខឲ្យច្រើនទេ គេរៀនតែវិធីសង្គ្រាម វិធីបាញ់ សំរាប់ធ្វើជាស្តេចក្រាញ់ រស់នៅដោយសង្គ្រាម ដោយប្រមាញ់ ។

ចំណែកខាងពួកសាសនា គេមានសាលារបស់គេ គេមានវិធីបង្រៀនស្របនឹងគោលបំណងវណ្ណៈគេ ។ សាលាអស់នោះទទួលក្មេងគ្រប់វណ្ណៈ បង្រៀនឲ្យចេះមើល ឲ្យចេះសរសេរ ឲ្យចេះគូរលេខបន្តិចបន្តួចមែន ពិតតែគេមានគោលបំណងមួយគឺ ៖ ហ្វឹកហ្វឺនក្មេងឲ្យទៅជាមនុស្សគ្រាន់តែចាំជឿមិនបាច់យល់អ្វី ឲ្យទៅជាមនុស្សអ្នកជឿស្លុងដើម្បីប្រយោជន៍វណ្ណៈគេ ។

ដល់ពេលដែលវណ្ណៈគហបតីមានជ័យជំនះឡើង គេស្ថាបនាសាលារបស់គេ ដោយមានគោលបំណងស្របទៅតាមប្រយោជន៍វណ្ណៈគេ ។ គេបង្ហាត់បង្រៀនឲ្យចេះមើល សរសេរ លេខវិទ្យាសាស្ត្រ ដើម្បីឲ្យជនវណ្ណៈគេទៅជាអ្នកជំនួញ អ្នកត្រួតត្រាធ្វើការជំនួសពួកត្រកូលអភិជន ដែលគេបាន

រលំរួបស្រេចទៅហើយៗ ក្នុងសតវត្សទី១៩នេះ មូលធននិយមក៏កើតឡើងៗ ពួកនេះបបួលគ្នាកែប្រែគោលបំណងទំនើបនៃការសិក្សាថ្មីទៀត ៗ គោលបំណងថ្មីនេះ គឺគ្រាន់តែហ្វឹកហ្វឺនប្រជាជនឲ្យទៅជាទាសនៃគ្រឿងចក្រសំរាប់តែបំពេញហោប៉ៅគេប៉ុណ្ណោះ ៗ គេបង្រៀនមើល បង្រៀនសរសេរ បង្រៀនលេខ បង្រៀនវិទ្យាសាស្ត្រដែរ តែគេខំកុហកប្រជាជនដែលជាអ្នកបង្កើតធនធានពិត ៗ សំរាប់គេនោះដោយពាក្យសំដីយ៉ាងផ្អែមល្ហែម ៗ ពាក្យសំដីអស់នោះគឺគេថាឲ្យសេរីភាព សមភាពដល់ប្រជាជនគ្រប់រូប ប្រជាជនទាំងអស់គ្នាត្រូវធ្វើការដើម្បីប្រយោជន៍ជាតិ សាសនាដែលជាប្រយោជន៍របស់ប្រជាជន ៗ គេថ្លែងនៅគ្រប់តំបន់គ្រប់ទំព័រសៀវភៅថា កូនប្រជាជន ណាក៏ដោយអាចនឹងរៀនវិជ្ជាសាស្ត្របាន អាចនឹងទៅជាអ្នកប្រាជ្ញបាន អាចនឹងកាន់ដំណែងធំៗបានទាំងអស់ តែតាមពិតគ្មានដែលមានកូនប្រជាជនណារៀនបានឆ្ងាយទេ ព្រោះខ្វះសាលារៀន ខ្វះសៀវភៅរៀន ខ្វះខាតសម្ភារៈគ្រប់មុខ ៗ កូនប្រជាជនមិនដែលបានឡើងទៅកាន់តំណែងណាមួយធំទេ ៗ មានអ្នកខ្លះរៀនបានឆ្ងាយដែរ បានជាអ្នកប្រាជ្ញ

ទំនើងគេខ្វះដែរ តែដោយសារខ្លួនគេ «ធ្វើជាអ្នកធំ» អ្នកនោះក៏គ្មានបានធ្វើ
អ្វីក្រៅពីស្មៀនគេ នៅក្នុងសាលាគេប្រើតែ «ទ្រឹស្ដីនិយម» អ្នករៀនបានទៅ
ជាអ្នកប្រាជ្ញមែនតែអ្នកប្រាជ្ញពេក គឺជាប្រកាន់តែទ្រឹស្ដីនិយម បើនិយាយ
ឡើងទៅ គឺបានតែនិយាយបានតែប្រាជ្ញ រកធ្វើអ្វីឲ្យមានប្រយោជន៍ដល់ប្រជា
ជនមិនកើត គិតតែប្រាជ្ញ ៗ អ្នកនោះអាល័យតែប្រាជ្ញ ពួកមូលធនិកបេះតែ
ក្រសារយកធនធានជាតិអស់ ៗ ដូច្នេះនៅពេលដែលពួកមូលធនិកកាន់អំណាច
ការសិក្សារបស់គេបំរើប្រយោជន៍វណ្ណៈគេ ដែលមានគ្រឿងចក្រជាឧបករណ៍
សំរាប់គ្របសង្កត់ប្រជាជន ៗ ការសិក្សារបស់គេមានគោលបំណងតែមួយគឺ
បង្ហាត់កូនប្រជាជនឲ្យទៅជាអ្នកជំនួយគ្រឿងចក្ររបស់គេតែប៉ុណ្ណោះ គេមិន
រវល់អប់រំ លើកស្ទួយកូនប្រជាជនឲ្យបានគ្រាន់បើឡើយ ៗ

តែក្នុងពេលឥឡូវនេះ កូនប្រជាជនជាច្រើនយល់ហើយ ភ្ញាក់ហើយ
ឃើញហើយនូវទ្រឹស្ដីកុហកនៃពួកមូលធនិក នូវការសិក្សាអាក្រក់ដែលជា
គ្រឿងបង្វែរកូនប្រជាជនពីកន្ទុងខ្ញុំ ៗ ៗ ប្រជាជនឃើញហើយនូវវាស-
នារបស់ខ្លួន ឃើញហើយនូវកម្លាំងរបស់ខ្លួន ចាប់ប្រមូលគ្នាតស៊ូដើម្បីកែប្រែ
ការសិក្សាព្រមទាំងរបៀបសិក្សា កម្មវិធីសិក្សាគោលបំណងសិក្សា ឲ្យស្រប
ទៅតាមរបបសង្គមជាតិ ដែលប្រជាជនប្រាថ្នាទឹងយកមកប្រើប្រាស់ ៗ

នេះជាដំណើរនៃការសិក្សាដែលយើងសង្កេតឃើញនៅក្នុងលោកយើងនេះ ។ ចំពោះប្រទេសខ្មែរយើងវិញ ការសិក្សាក៏មានប្រែប្រួលដែរ ។ កាលប្រទេសយើងនៅជាប្រទេសចំណុះគេ យើងដឹងស្រាប់ហើយថាគេគ្រប់សង្កត់យើងយ៉ាងណាក្នុងការស្វែងរកចំណេះវិជ្ជា ។

ដូចលោកគ្រូ-អ្នកគ្រូ មិត្តអ្នកអានជ្រាបស្រាប់ហើយ ពេលនោះពួកអាណានិគមនិយមគេយកសាលារៀនជាឧបករណ៍សំរាប់ជះជាន់យើង សំរាប់បម្រិតយកខ្លាញ់យើង ។ ដើម្បីគេធ្វើដូច្នោះបានគេយកភាសាគេជាធំ ជារបងមួយដើម្បីរាំងយើង ។ ម្យ៉ាងទៀតរបៀបបង្រៀន កម្មវិធីបង្រៀនក៏ជាគ្រឿងមួយទៀតដើម្បីកុំឲ្យយើងលូតលាស់បាន កុំឲ្យយើងកសាងអ្វីខ្លួនយើងកើត ឲ្យយើងចាំតែរកគេជួយ ។ ដូច្នោះការសិក្សានេះវាផ្ទុយស្រឡះពីប្រយោជន៍ខ្មែរ ពីប្រយោជន៍ប្រជាជនខ្មែរ ។

ឥឡូវនេះប្រទេសយើងបានឯករាជ្យហើយ ។ ត្រូវការអ្នកកសាងណាស់ ដូច្នេះយើងត្រូវបង្កើតសាលាឲ្យរឹតតែបានច្រើនទៅទៀត ដើម្បីនឹងឲ្យពលរដ្ឋខ្មែរគ្រប់រូបបានក្រេបជញ្ជក់យកជំរះវិជ្ជា ។ កម្មវិធីទៀតក៏ត្រូវកែប្រែ ត្រូវតែបង្រៀនជាភាសាខ្មែរ របៀបបង្រៀនវិញក៏ដូច្នោះដែរ បានសេចក្តីថាយើងធ្វើយ៉ាងដូចម្តេចឲ្យកម្មវិធី ឲ្យរបៀបបង្រៀនស្របទៅតាមប្រយោជន៍ជាតិយើង

ស្របទៅតាមឋានៈនៃប្រទេសយើង ។

យើងទៀតទុកការនេះ សរសើរដល់រាជរដ្ឋាភិបាលដែលបានប្រកាសជាឧឡារិកថា សាលាត្រូវតែបង្រៀនជាភាសាខ្មែរ ហើយនៅក្នុងផែនការណ៍ពីរឆ្នាំ រាជរដ្ឋាភិបាលបានប្ដេជ្ញានឹងបង្កើតសាលាឲ្យបានគ្រប់ប្រជុំស្រុក ថែមទាំងបង្កើតឲ្យមានមហាវិទ្យាល័យថែមទៀត ។

រាជរដ្ឋាភិបាលបានប្រកាសយ៉ាងនេះក៏ពិតមែនហើយ តែចំណែកយើងវិញ ហើយពិសេសលោកគ្រូ អ្នកគ្រូ មាតាបិតាក្មេងទាំងឡាយក៏មិនត្រូវព្រងើយកន្តើយនឹងរឿងនេះដែរ ត្រូវតែយើងជួយមតិ ជួយឧបត្ថម្ភដល់រដ្ឋាភិបាល ប្រមូលផ្ដុំជាសមាគមក្ដីឬដោយឯកឯងក្ដី ធ្វើយ៉ាងណាឲ្យបំណងយើងគឺកសាងប្រទេសជាតិបានរហ័ស ។ យើងធ្វើនេះទៀតគឺដើម្បីឲ្យកូនសិស្សយើង កូនយើងចេះពិតប្រាកដ ស្គាល់ដម្លៃអក្សរសាស្ត្រខ្មែរ ស្គាល់វប្បធម៌ខ្មែរ យកចំណេះមកបម្រើប្រយោជន៍រួម មិនមែនយកចំណេះមកកសាងអាត្មាឲ្យលើសលុបហួសប្រមាណនោះទេ ។ ដែលធ្វើយ៉ាងនេះបានលុះត្រាតែយើងម្នាក់ៗ

ទាត់ចោលគំនិតយល់ខុសដែលថាត្រូវតែរៀនភាសាបារាំងទើបបានជាអ្នកចេះពិតប្រាកដនេះម្យ៉ាង នឹងមិនព្រមកែប្រែកម្មវិធីបង្រៀនឲ្យស្របទៅតាមរបបសង្គមមិនព្រមកែប្រែសាលាយើងឲ្យទៅជាសាលាប្រជាជននេះម្យ៉ាងទៀត ។

(ចប់)

---

## នៅសាលាដំបូង

— នាងឯងអាយុប៉ុន្មាន ?

នារីដែលជាប់ចោទ ទ្រង់អេះអញគិតបន្តិចសិន ។

ចៅក្រមឃើញថ្លូឆ្លោះ ក៏ប្រាប់ថា

— នាងឯងគិតយូរ អាយុកាន់តែច្រើន ។

## ចំឡែក !

— សេះដែលអ្នកលក់ឲ្យខ្ញុំពីម្សិល ងាប់ព្រឹកមិញទៅហើយ

— ខ្ញុំជិះវាបរលោកតែប៉ុណ្ណោះ កាលវានៅនឹងខ្ញុំ វាមិនធ្លាប់ធ្វើ-អីចឹងសោះ ។

[illegible]

[illegible]

[illegible]

(១)

---

[illegible]

# រើសមុខងារជាការចាំបាច់

ប្រវត្តិសាស្ត្រនៃប្រទេសខ្មែរយើង ទើបនឹងបើកទំព័រមួយថ្មី ។ អតីតកាលដែលជនខ្មែរគ្រប់រូបបានប្រទះឃើញជាក់ស្ដែងដោយខ្លួនឯង ទើបនឹងកន្លងផុតក្នុងកំឡុងពេលថ្មី ៗ នេះដែរ ។

សម័យនេះ គឺសម័យដែលប្រទេសខ្មែរយើងមានបរិយាកាសក្សាន្តជ្រះស្រឡះជាប្រទេសឯករាជ្យយ៉ាងបរិបូរណ៍ ក្នុងបណ្ដាប្រទេសនានាលើពិភពលោក ។ ប្រជាជនខ្មែរយើងគ្រប់រូបតាំងពីបណ្ឌិតរហូតដល់កម្មករ កសិករ បានភ្ញាក់រលឹក ស្ទុះស្ទាញឡើង ប្រុងស្មារតី ខិតខំបំពេញមុខការមុខងារឲ្យបានហ្មត់ចត់ដោយមានបំណងដើម្បីនឹងជម្រុញប្រទេសយើងឲ្យដល់សេចក្ដីចំរើនបរិបូណ៌ ខាងផ្លូវសេដ្ឋកិច្ច វប្បធម៌ ។

សេដ្ឋកិច្ច ពាក្យមួយម៉ាត់នេះមានន័យវែងឆ្ងាយណាស់ ហើយធ្វើឲ្យយើងគ្រប់រូបរមិលមើលឃើញទៅអនាគត ការចំរើនជឿនលឿនរបស់ប្រទេសយើងនឹងជីវភាពខ្ពង់ខ្ពស់នៃប្រជាជន ។ សំឡឹងឃើញអនាគតល្អប្រពៃយ៉ាងដូច្នេះ យើងតែងតែមានសេចក្ដីសប្បាយរីករាយធំជាអនេក ព្រោះ

យើងសង្ឃឹមនៅក្នុងចិត្តបំណងស្រេច ថាយើងមុខជាឈានទៅដល់កំរិតខ្ពង់ខ្ពស់នោះជាមិនខាន ។

តែយើងត្រូវដឹងថាពីសម័យកាលនេះ ទៅដល់អនាគតជិតខាងមុខនេះ ប្រទេសយើងរំពឹងទាំងស្រុងលើកម្លាំងមហាសាលរបស់ប្រជាជន លើកម្លាំងយុវជនខ្មែរទូទៅ ដែលនៅក្នុងវ័យកំពុងខិតខំរៀនស្វែងរកវិជ្ជាគាប់ប្រសើរតាមបំណង ដើម្បីនឹងទៅបំរើមាតុប្រទេសនៅក្នុងអនាគតដ៏ឆាប់ ៗ នេះ ។

ជំនាន់សម័យអាណានិគមនិយម ប្រទេសខ្មែរយើងគ្មានអ្នកជំនាញអ្នកចេះជ្រៅជ្រះ ធំបំផុតខ្លះអ្នកបច្ចេកទេសដូចជាវិស្វករ បណ្ឌិតខាងវិទ្យាសាស្ត្រផ្សេង ៗ ។ កេរ្តិ៍តំណែលនេះជិតជាប់មកដល់បច្ចុប្បន្នកាលឯករាជយើងនេះទៀត ។ ឧបសគ្គៈនេះហើយ ដែលធ្វើឲ្យសេដ្ឋកិច្ចយើងឈានដើរទៅមុខមិនបានជឿនលឿនសោះ ។ ខ្វះទាំងសម្ភារៈ ខ្វះទាំងបុគ្គលិកបំណាន ៗ ដើម្បីនឹងប្រើប្រាស់ប្រតិបត្តិការតាមលំអានដែលយើងត្រូវការជាដាច់ខាត ។

បើយើងខ្វះបុគ្គលិកបំណាន ៗ សំរាប់កសាងជឿនសេដ្ឋកិច្ចយើងដូច្នេះ យុវជនខ្មែរយើងត្រូវសំដៅចំណេះវិជ្ជាខាងវិទ្យាសាស្ត្រឲ្យបានភាគច្រើន ដើម្បីនឹងបំពេញកន្លែងចន្លោះនេះឲ្យឆាប់រហ័សទាន់ពេលវេលា ។ យុវជនខ្មែរត្រូវស្រឡាញ់មុខងារខាងបច្ចេកទេសឬខាងវិទ្យាសាស្ត្រឲ្យអស់ពីចិត្ត ។

មិនត្រូវមើលងាយឬយល់ថា ជាមុខងារមិនសមរម្យឬក្រខ្វកក្រខ្វក់ធ្វើឲ្យប្រលាក់ស្អុះស្អាប់មុខមាត់ឲ្យសោះ ៗ ផ្ទុយទៅវិញ មុខងារខាងបច្ចេកទេសឬខាងវិទ្យាសាស្ត្រមានថ្នាក់កិត្តិយសខ្ពស់បំផុត ចំពោះមុខងារផ្សេង ៗ ទៀត ៗ នៅក្នុងប្រទេសឯករាជនីមួយ ៗ ធំផុតប្រទេសទើបនឹងបានឯករាជថ្មី ៗ យុវជនប្រទេសគេ ខំសូត្ររៀនណាស់ ហើយច្រើនតែសង្កាត់ទៅខាងផ្នែកវិទ្យាសាស្ត្រនិងខាងបច្ចេកទេស ដោយយុវជនប្រទេសនោះយល់ច្បាស់នូវអនាគតរបស់ប្រទេស និងករណីយកិច្ចរបស់ពលរដ្ឋម្នាក់ ៗ ឆ្ពោះទៅមាតុប្រទេស ៗ

ក្នុងប្រទេសយើងវិញ យុវជនខ្មែរ ក៏បានភ្ញាក់រលឹកច្រើនណាស់ដែរ នៅត្រង់ចំណុចនេះ ៗ យុវជនខ្មែរ មានចិត្តស្រឡាញ់ចូលចិត្តរៀនច្រើនខាងចំណោះតិកនិកនិងវិទ្យាសាស្ត្រ ៗ ការជឿនលឿននេះ បានធ្វើឲ្យប្រទេសយើងឈានទៅខាងមុខបានមួយជំហានហើយ តែជំហាននេះឈានបានខ្លីពេកហើយយឺតផង ៗ ដូច្នេះបើចង់ឲ្យប្រទេសយើងឈានបានវែងហើយឆាប់ តោងយុវជនខ្មែរយើង សូត្ររៀនខាងចំណោះបច្ចេកទេសឲ្យបានភាគច្រើនជាងនេះទៅទៀត ដើម្បីនឹងជួយដ្រំកម្លាំងកសាងសេដ្ឋកិច្ច ប្រទេសយើងឲ្យបានជឿនលឿនជាងនេះទៅទៀត នៅក្នុងពេលឆាប់ៗខាងមុខនេះ ៗ

មុខងារប្តូរជំនាញការខាងផ្នែកតិកនិកនិងវិទ្យាសាស្ត្រមានប្រយោជន៍ពិសេសណាស់ដល់ប្រទេសដល់ប្រជាជនយើង ។ ប្រយោជន៍នេះគឺប្រយោជន៍រួមពិត ។ បើយើងចេះប្រើជំរេះវិជ្ជាដែលមាននៅក្នុងខ្លួន ។ ជំរេះវិជ្ជាណាបំរើប្រយោជន៍ប្រជាជន មាតុប្រទេស ជំរេះវិជ្ជានោះហៅថា សុវិជ្ជា ពិតប្រាកដ ។

---

## ពាក្យក្មេង

កូនតូចអាយុ ៥ ឆ្នាំ·— ប៉ា! ឡានធំនុ៎ះម៉េចក៏វាទៅមុខ?

ឪពុក·— ព្រោះវាមានម៉ាស៊ីន

កូន·— បើអញ្ចឹងម៉េចក៏ប៉ាមិនទិញម៉ាស៊ីនដាក់ផ្ទះយើង ឲ្យវាទៅមុខជិតសាលាខ្ញុំ ។

# ប្រវត្តិសាស្ត្រ

## ប្រវត្តិនៃសង្គមមនុស្ស

ក្នុងលោកយើងនេះ គ្មានអ្វីនៅនឹងទេ ។ រុក្ខជាតិ សត្វ មនុស្ស ទាំងឡាយតែងតែផ្លាស់ប្ដូរ តែងតែប្រែប្រួលជានិច្ច ។ សូម្បីតែថ្មក៏មានប្រវត្តិវាដែរ វិទ្យាសាស្ត្របានបង្ហាញថាថ្មមានកំណើតរបស់វា មានអាយុរួចក៏រលាយសាបសូន្យទៅវិញ ។ ផែនដីយើងក៏ដូច្នោះដែរ មិនមែនកើតមកស្រាប់ដូចយើងឃើញសព្វថ្ងៃនេះទេ ។

បើយើងមើលមកមនុស្សវិញ យើងឃើញថាពីដើមមនុស្សរស់នៅជាហ្វូង ជាក្រុម រហូតមកដល់ឥឡូវប្រមូលផ្ដុំគ្នាជានគរ ជាប្រជាជាតិ ។ ប្រដាប់ប្រដាដែលមនុស្សប្រើនោះសោត ក៏ប្រែប្រួល គឺតាំងពីប្រើពូថៅថ្មដំបង រហូតមកដល់គ្រឿងចក្រ គ្រឿងម៉ាស៊ីនដែលយើងប្រើប្រាស់សព្វថ្ងៃ ។ ដូច្នេះការវិវត្តន៍ជាច្បាប់ធម្មជាតិមួយ ។ ម្យ៉ាងទៀតប្រវត្តិសាស្ត្របានដៅទុកមកឲ្យឃើញថាការវិវត្តន៍នេះទៅមុខជាដរាប គឺថាវិវត្តពីទាបទៅ

រស់ បានសេចក្ដីថាធម្មជាតិចំរើនជានិច្ច ប្រវត្តិសាស្ត្រដើរទៅមុខជាដរាបៗ ក្នុងទីនេះយើងយកច្បាប់ធម្មជាតិនេះមកពិចារណាដំណើរនៃសង្គមមនុស្ស ។

ចាប់តាំងពីមានមនុស្សនៅលើទឹកដីនេះ មនុស្សតែងតស៊ូនឹងធម្មជាតិជានិច្ចកាលដើម្បីរស់ ។ ក្នុងការតស៊ូនេះមនុស្សមិនអាចនៅ មិនអាចតស៊ូតែម្នាក់ឯងបានទេ មនុស្សតែងតែប្រមូលផ្ដុំគ្នាជាហ្វូង ជាក្រុម ។ បើមិនដូច្នោះទេ មនុស្សនឹងទៅជាចំណីសត្វសាហាវដែលនៅតែពាសពេញ ។ នៅពេលនោះគេប្រើថ្ម ប្រើឆ្អឹងសត្វជាអាវុធសំរាប់ប្រកបការចិញ្ចឹមជីវិត ។ ការរស់នៅ ។ ដោយវេទនា មនុស្សមិនទាន់ចេះដាំដំណាំ មិនទាន់ចេះចិញ្ចឹមសត្វធាតុទេ ។ ការរស់នៅដោយលំបាកយ៉ាងនេះ ធ្វើឲ្យហ្វូង ក្រុមឬកុលសម្ពន្ធទាំងនោះមានការទាស់ទែងរវាងគ្នាដណ្ដើមទីជាញឹកញាយ ។ ដូច្នោះការប្រកាប់ប្រចាក់ ការតយុទ្ធរវាងគ្នាមានជាញឹកញាយដែរ ។ នៅពេលនោះគេសង្កេតឃើញថា គេមិនដែលទុកឈ្លើយសឹកទេ ឬមួយគេនាំគ្នាស៊ី ឬមួយគេយកឈ្លើយអស់នោះទុកជាកូនជាចៅក្រុមគេ ហ្វូងគេទៅ ។ ការស៊ីមនុស្សដូចគ្នានេះ មិនមកពីអ្វីទេ គឺមកពីការខ្វះខាតខាងម្ហូបចំណី ។

នៅក្នុងហ្វូងក្នុងក្រុមនីមួយ ៗ វិញ គេមិនឃើញមានការជិះជាន់សង្កត់

សង្កិនគ្នាទេ ។ គ្មានវណ្ណៈទេ គ្មានការរំលោភហួងហែងយកមានតែឯងទេ ការពិតទៅវា គ្មានអ្វីធ្វើជាទ្រព្យសម្បត្តិសម្រាប់ទុកដាក់ផង ។ នៅពេលនោះ មនុស្សគ្រប់ប្រភេទធ្វើការគ្រប់ៗគ្នា ។ របស់ដែលគេបាន ដូចជាសត្វដែលបាញ់បាន ផ្លែឈើដែលបេះបាន គេយកមកចែកស្មើៗគ្នា ។ របបធំនៅពេលនោះគឺប្រមាញ់ ។ សង្គមរបៀបនេះ គេហៅថាសង្គមសមុហភាពបុព្វកាល ។

ក្នុងសង្គមនេះ យើងអាចសង្ខេបបានដូចនេះ ៖

១– ប្រដាប់ប្រដាបង្កើនផល មានពូថៅថ្ម ដំបង សន្ទូច ធ្នូ ។

២– លក្ខណៈធំរបស់សង្គមនេះ ៖ សង្គមទាំងមូលជាម្ចាស់ផលិតកម្ម ។

៣– ការរស់នៅ ៗ ដោយវេទនា ។

បន្ទាប់មក បញ្ញាមនុស្សរួមនឹងការពិសោធន៍ក្នុងការរស់នៅជំរុញមនុស្សឲ្យចេះដាំដំណាំ ចេះចាប់សត្វយកមកចិញ្ចឹម ។ ដូច្នោះការរស់នៅបានចំរើនជាងមុន មនុស្សមិនសូវខ្វះខាតដូចមុន មនុស្សមានពេលគិតដល់ការចំរើនក្នុងជីវភាពទៀត ។ ការរស់របៀបនេះជំរុញមនុស្សឲ្យមានគំនិតផ្សេងពីជាន់មុន ។ ផលបានពីដំណាំ បានពីការចិញ្ចឹមសត្វអាចទុកធ្វើជាទ្រព្យ ធ្វើជាសម្បត្តិ កាលណាមានទ្រព្យសម្បត្តិបរិបូណ៌ ការរស់នៅក៏កាន់តែស្រួល ។

ពីដើមមនុស្សដើរត្រាច់រកម្ហូបចំណីតាមព្រៃតាមផ្សៃ ឥឡូវមនុស្សមិនចាំបាច់ទៅឆ្ងាយទេ គ្រាន់តែរកចំការស្រែឲ្យបានច្រើន ឬចិញ្ចឹមសត្វឲ្យបានច្រើន ឃើញថាបរិបូណ៌ណាស់ហើយ ។ តែការស្វែងរកស្រែចំការនេះតែងតែមានទំនាស់ទាស់គ្នាជានិច្ច ។

ការនេះធ្វើឲ្យមនុស្សមានចិត្តហួងហែងចង់លោភ ។ ក្នុងការហួងហែងឲ្យបានច្រើននេះអាចធ្វើឲ្យមានបញ្ហាមួយកើតឡើង គឺម្នាក់ឯងនឹងគ្រួសារឯងធ្វើមិនសូវបានច្រើនទេ ត្រូវទីពឹងកម្លាំងគេទៀត ។ ដូច្នេះនៅពេលនោះ គេឃើញថាការយកឈ្លើយសឹកមកស៊ីឬយកមកចិញ្ចឹមវាខាត គេកេណ្ឌអ្នកអស់នោះមកធ្វើជាទាសាវិញ គ្រាន់ជាកម្លាំងមួយសំរាប់បង្កើនផលឲ្យគេ ។ ទាសាទាសីអស់នោះ ធ្វើការឲ្យគេទាំងអស់ ខ្លួនឯងគ្រាន់តែបានរស់ប៉ុណ្ណោះ ឯប្រដាប់ប្រដាប្រើប្រាស់នៅពេលនោះវិញក៏បានចំរើនជាងមុនដោយមនុស្សចេះយកដែកស្ពាន់មកប្រើធ្វើជាអាវុធ ។ តែការចំរើនផលវិញផ្អែកទៅលើកម្លាំងមនុស្សទាំងអស់គឺកម្លាំងទាសា ។ ការហត្ថកម្មក៏ចាប់កើតមាន ។ ដំបូងគ្រាន់តែកើតសំរាប់គ្រួសារឯងទេ តែដល់ការត្រូវការកាន់តែច្រើនឡើងនៅក្នុងសង្គម ការងារទាំងឡាយ ក៏កាន់តែបែកមុខងារច្បាស់លាស់ឡើង ។ ជំនួញដែលកើតដំបូងពីការដូររបស់គ្នាប្រើប្រាស់ក៏

កាន់តែចំរើនឡើងជាលំដាប់ ៗ នៅក្នុងសង្គមនោះ មនុស្សបែកជាពីរពួក មួយពួកគឺពួកអ្នកជា នឹងអ្នកម្ចាស់ ទាសាទឹងដំនាងមួយពួកទៀតគឺពួកទាសា ៗ ពួកអ្នកជាមានសិទ្ធិសេរីភាពគ្រប់យ៉ាង ឯពួកទាសាវិញគ្មានសិទ្ធិគ្មានអំណាចអ្វីទេ អ្នកអស់នេះ មានតែកម្លាំងសំរាប់ធ្វើការឲ្យគេ ប្រដាប់ប្រដាប្រើប្រាស់ក៏មិនមែនជារបស់ឯងផង ហើយគេអាចលក់ទិញដូរ ឬសម្លាប់ទាសានេះបានតាមចិត្ត ៗ ការងាររបស់ទាសាជាការងារដោយបង្ខំ ៗ សង្គមរបៀបនេះ គេហៅថាសង្គមទាសភាព ៗ ដោយសង្ខេបលក្ខណៈរបស់សង្គមនេះមានដូចខាងក្រោម ៖

១– ប្រដាប់ប្រដាប្រើប្រាស់ធ្វើដោយលោហធាតុមាន ដែក ស្ពាន់ជាដើម ៗ

២– ពួកចៅហ្វាយជាម្ចាស់លើផលិតកម្មទាំងមូលរួមមានទាសាផង ៗ

៣– ការរស់នៅគ្រាន់បើជាងមុន ៗ

តមកទៀត ការចំរើនខាងផលិតកម្ម ធ្វើឲ្យសង្គមទាសភាពប្រែក្លាយទៅជាសង្គមសក្តិភូមិ ៗ លក្ខណៈមួយនៃសង្គមនេះ គឺគ្មានវណ្ណៈទាសាទៀតទេ ៗ

ការរស់នៅបានចំរើនធ្វើឲ្យមនុស្សម្នាក់ ៗ មិនអាចចិញ្ចឹមទាសាទាសី

ទាំងហ្វូងៗដូចមុនបានទេដោយៈ

១ – របៀបការងារដោយបង្ខំយ៉ាងនេះធ្វើឲ្យផលិតកម្មមិនចំរើន គឺធ្វើការតាមតែគេប្រាប់គេបញ្ជា ។

២ – ប្រដាប់ប្រដាបង្កើនផលចំរើនទៅ ដោយមនុស្សចេះប្រើនង្គ័ល ដោយមានសត្វអូសជំនួសកម្លាំងមនុស្ស ។ ដូច្នេះចំពោះពួកទាសាពីដើម គេចែកដី ចែកធ្វើឲ្យអ្នកអស់នោះប្រកបការរកស៊ី គ្រាន់តែដីនៅជារបស់ទ្រព្យគេដដែល ម្យ៉ាងទៀត អ្នកដែលរកស៊ីនៅលើដីណា ជាប់ជំពាក់នៅលើដីនោះ គឺថាបើម្ចាស់ដីសេដ្ឋីគេលក់ដីកន្លែងណាមួយ គេលក់ទាំងមនុស្សដែលរកស៊ីនៅលើដីនោះ ។ ឯចំណែកសេដ្ឋី ពួកស្តេចក្រាញ់វិញ គេរស់នៅដោយយកពន្ធអាករលើដីរបស់គេនោះ គេគ្រាន់តែទុកផលបន្តិចបន្តួចឲ្យអ្នកបង្កើតផល ឃើញថាពិតមែនតែមនុស្សបានសិទ្ធិសេរីភាពខ្លះតែការជិះជាន់តែបម្រាញ់យកផលនៅតែខ្លាំងដដែល ។ ក្នុងសង្គមសក្តិភូមិ មនុស្សចែកជាពីរវណ្ណៈធំៗ គឺវណ្ណៈម្ចាស់ដីសេដ្ឋីមួយ វណ្ណៈពួកបង្កើតផលផ្ទាល់មួយ ។ មានវណ្ណៈឯទៀតៗដែរ នៅពេលនោះ គឺពួកជំនាង ពួកហត្ថករ ពួកគហបតី ។ ដូចយើងបានឃើញខាងលើនេះ ក្រៅពីការធ្វើស្រែចំការ មានមុខរបរឯទៀតៗ ដូចជាតម្បាញ ការហត្ថកម្មផ្សេងៗដែលចេះតែ

រីកចេះតែចំរើន ឯសម្បត្តិទ្រព្យសង្គមវិញ គឺសម្បត្តិដែលកើតមកពីការបង្កើន ផលធ្លាក់មួយផ្នែកធំទៅលើវណ្ណៈសេដ្ឋីសក្តិភូមិ នៅសល់បន្តិចបន្តួចបានដល់ ទៅវណ្ណៈឯទៀត ៗ ។ នៅពេលនោះ លុះដោយអំណាចការចំរើននៃការ បង្កើនផល ក៏បានជំរុញវិទ្យាសាស្ត្រឲ្យកាន់តែលូតលាស់ណាស់ដែរ ។ ត្រឡប់មកវិញវិទ្យាសាស្ត្រក៏ជួយចំរើនការបង្កើនផលវិញ ។ ដោយសង្ខេប សង្គមសក្តិភូមិមានលក្ខណៈ៖

១- ប្រដាប់ប្រដាប្រើប្រាស់ចំរើន មនុស្សចេះស្លដែក លោហធាតុ ឯទៀត -

២- វណ្ណៈធំ គឺវណ្ណៈសេដ្ឋីដែលជាវណ្ណៈជិះជាន់គេ និងវណ្ណៈបង្កើតផល ផ្ទាល់ ។

៣- វិទ្យាសាស្ត្រកាន់តែចំរើន ការរស់នៅកាន់តែស្រួល ។

ក្រោយមកការចំរើននៃវិទ្យាសាស្ត្រដែលនាំឲ្យការជំនួញជួញប្រែកាន់ តែលូតទៀត ធ្វើឲ្យការបង្កើតផលចំរើនខ្លាំងឡើង ។ ចំពោះមុខការចំរើននេះ គ្របខណ្ឌរបបសក្តិភូមិជាឧបសគ្គធំណាស់ ។ ដូច្នោះសង្គមសក្តិភូមិមិនអាចរស់ នៅទៀតបាន ក៏ទុកឲ្យសង្គមមូលធននិយមឡើងម្ដងវិញ ។ ក្នុងការប្រែ ប្រួលសង្គមនេះគ្មានអ្វីចំឡែកទេ ។ បើមើលទៅមនុស្សនៅក្នុងសង្គមនោះគេ

ឃើញមានមនុស្សមួយពួកជាអ្នកជិះជាន់សង្កត់សង្កិនគេ គឺពួកមូលធនិក មនុស្សមួយពួកទៀតត្រូវគេជិះជាន់ គឺពួកកម្មករ កសិករ ៗ តែបើមើលខាងសិទ្ធិមនុស្សឃើញថាចំរើនជាងពេលមុន តែចំរើននេះគឺដោយការរស់នៅ ការចំរើនផលវាជំរុញទៅផងដែរ ៗ ក្នុងពេលនេះមនុស្សទាំងអស់មានសិទ្ធិសេរីភាពទាំងអស់គ្នា មនុស្សត្រូវបានរៀនសូត្រទាំងអស់គ្នា ព្រោះក្នុងការបង្កើនផលគេត្រូវការមនុស្សចេះគួរសម ចេះមានដើមគំនិតគ្រាន់បើដើម្បីទៅកាន់កាប់គ្រឿងចក្រ ៗ មនុស្សទាំងអស់មានសិទ្ធិសេរីភាពក៏មែនពិត តែមនុស្សទាំងអស់ គឺសង្គមទាំងមូលមិនមែនជាម្ចាស់ប្រដាប់ប្រដាបង្កើនផលនោះទេ ៗ មានតែជនមួយពួកដែលជាចំនួនតិចគឺពួកមូលធនិកទេដែលជាម្ចាស់សម្ភារៈអស់នោះ ៗ នៅស្រែចំការវិញការភ្ជួររាស់ក៏កាន់តែលែងប្រើកម្លាំងសត្វជាតុទៀតហើយ គេប្រើកម្លាំងម៉ាស៊ីនវិញ ៗ

កម្លាំងបង្កើនផលខ្លាំងយ៉ាងនេះ ធ្វើឲ្យរបបមូលធននិយមមានវិបត្តិជាញឹកញយ ៗ ការបង្កើតផលបានច្រើន ធ្វើឲ្យតម្លៃវត្ថុចុះថោក ឯការប្រកួតប្រណាំងដេញដើមគ្នាក៏កាន់តែខ្លាំង ចំណែកមហាជនវិញកាន់តែក្រទៅ រកលុយទិញវត្ថុដែលមានពុំបាន ៗ ដូច្នោះវត្ថុដែលកើតច្រើនរកមនុស្សទិញគ្មាន នាំឲ្យមានវិបត្តិសេដ្ឋកិច្ច ៗ ការចង់ចំណេញហួសប្រមាណធ្វើឲ្យ

ការទាស់ទែងរវាងវណ្ណៈកាន់តែខ្លាំងឡើង រឹតតែចេញមុខឡើង ៗ នេះជារបបមូលធននិយម នៅស្រុកខ្លះវិញសព្វថ្ងៃគេកាត់ចោលរបបនេះទៅហើយ ៗ គេយករបបសង្គមនិយមមកប្រើវិញ ៗ នៅក្នុងសង្គមនេះប្រដាប់ប្រដាសំរាប់បង្កើតផលជាទ្រព្យជាសម្បត្តិរបស់សង្គមទាំងមូល ៗ

នៅក្នុងសង្គមនេះគ្មានអ្នកជិះជាន់មនុស្សទេ ៗ ការទាក់ទងផលិតកម្មវិញក៏ជាការទាក់ទងដោយស្មោះស្ម័គ្រដោយមេត្រី ៗ នៅក្នុងសង្គមមុន ៗ គេទុកប្រាក់ជាធំ គឺថាបើគ្មានប្រាក់គេមិនអាចធ្វើអ្វីកើតទេ ៗ នៅក្នុងសង្គមនិយមវិញ គេទុកការងារជាធំប្រាក់កាសជាបន្ទាប់បន្សំជារបស់កើតក្រោយការងារ ៗ ការបង្កើតផលគេធ្វើទៅតាមផែនការសម្រេចតាមការត្រូវការរបស់សង្គម ដូច្នោះគេមិនឃើញមានការវិបត្តិសេដ្ឋកិច្ចដូចនៅក្នុងរបបមូលធននិយមទៀតទេ ៗ

នេះគឺជាប្រវត្តិដោយសង្ខេបនៃសង្គមមនុស្សដែលមាននៅក្នុងលោកនេះ ៗ តែដំណើររបស់សង្គមដែលយើងបានឃើញទ្រួស ៗ នៅក្នុងទីនេះមិនមែនមានដំណើរដាច់ ៗ គ្នាទេ ហើយការវិបត្តិនេះទៀតក៏មិនមានស្មើគ្នាដែរ ៗ សង្គមទាំងប្រាំដែលបាននិយាយមកនេះ គេអាចសង្កេតឃើញមាននៅពេលឥឡូវនេះទៀត ដូចកាលពី៤ឬ៥ឆ្នាំមុននេះមានបេស

កម្មករប្រាជ្ញមួយពួកបានទៅស្រុកអាមេរិកខាងត្បូង ហើយជួបប្រទះ នឹង សង្គមមនុស្សខ្លះ ដែលរស់នៅជារបៀបជាន់ដើម មិនដែលស្គាល់អារ្យធម៌ សម័យយ៉ាងដូចម្តេចទេ ៗ នៅក្នុងប្រទេសខ្មែរយើងនេះ ក៏ប៉ុន្មានឆ្នាំមុនក៏មាន ដែរ គឺពួកពនងកួយ ៗលៗ ម្យ៉ាងទៀតកាលពីខែមុននេះ យើងរាល់គ្នាក៏បានឮ ថានៅក្នុងអង្គការសហប្រជាជាតិ គេទើបបានសម្រេច បំបាត់របបទាសភាព ឲ្យអស់ចេញ ៗ បើយើងរកមើល រកឧទាហរណ៍ជាក់ស្តែង ឃើញនៅ មានច្រើនទៀត ៗ

តែគួរយើងនាំគ្នាមកពិចារណារឿងនេះវិញ ម្យ៉ាងយើងឃើញថា សង្គម មនុស្សមានដំណើររបស់ខ្លួនមួយហើយ មានការវិវត្តន៍ ម្យ៉ាងទៀតយើងឃើញ ថាក្នុងដំណើរនេះ សង្គមទាំងអស់មិនមែនមានការវិវត្តន៍ដូចគ្នាទេ មាន សង្គមខ្លះឈានដើរលឿនខ្លះទៀតយឺត ៗ យើងគួរចោទសួរថា « តើអ្វីដែល ធ្វើឲ្យសង្គមដើរលឿនឬយឺត? ហេតុដូចម្តេច ក៏មានប្រទេសកាន់របប នេះ ប្រទេសនោះកាន់របបនោះ? ៗ

សំនួរនេះគួរយើងពិចារណា ព្រោះសំខាន់ដែរ ។ យើងសូមឲ្យអស់លោកអ្នកអានទាំងឡាយជួយឆ្លើយផង . ព្រោះម្យ៉ាងចំឡើយនេះនាំឲ្យយើងចេះ ម្យ៉ាងទៀតនាំឲ្យយើងដោះស្រាយការរស់នៅរបស់យើងសព្វថ្ងៃ ដែលមានការទាក់ទងទៅបញ្ហាប្រទេសយើង ។

---

## សប្បាយផង !

ទេសចរម្នាក់ឈរនៅលើថ្មអង្គរវត្តថា

– ខ្ញុំបានមកដល់ទីនេះជាមួយប្រពន្ធខ្ញុំ ; សប្បាយណាស់ !

ក្រោយមកទេសចរម្នាក់ទៀតទៅដល់កន្លែងនោះ ហើយឈរពីខាងក្រោមថា

– ខ្ញុំបានមកដល់ទីនេះឥតប្រពន្ធ; សប្បាយជាងទៅទៀត !

# បញ្ហាអនាម័យ

## អនាម័យទារក

(ស្រង់យកយោបល់ខ្លះ ពីលោកវេជ្ជបណ្ឌិត បញ្ញាវីយ៉ាឡាត)

អនាម័យទារក ប្រែថាវិធីចិញ្ចឹមកូនតាមក្បួនខ្នាត ។ ចំណុចនេះ ខ្ញុំសូមបញ្ជាក់ថាអនាម័យនេះសំដៅទៅលើតែទារក ដែលប្រកបដោយសុខភាពបរិបូណ៌ហើយការពារទារកដែលកើតមកមានជម្ងឺមតិក ឬ មានជម្ងឺតមកទៀត, ការៈ ធ្លាក់ទៅលើពេទ្យជាដាច់ខាត ។

កាលបើទារកកើតចេញពីផ្ទៃពោះម្ដាយ (ខ្ញុំប្រើពាក្យផ្ទៃពោះ ដើម្បីជាកិច្ចសំរាប់យល់ព្រោះធម្មតាទារកនៅក្នុងស្បូន ) គ្រូពេទ្យឬឆ្មបសង្កេតមើលរូបកាយទាំងស្រុងគឺសង្កេតមើលស្បែក តើស្បែកនោះ ស្អាតឬមានពងបែកទឹករងៃដែលជាសញ្ញា១របស់រោគស្វាយជាមតិក ទ្រង់ទ្រាយខ្លួនប្រាណ ជាទារកធម្មតា ឬស្គមពោះកំប៉ោង ចេញឆ្អឹងជំនីរគឺងមានសភាពដូចជាមនុស្សចាស់ជរា, ភ្នែកស្អាតឬមានខ្ទុះ(ចំពោះរឿងភ្នែកទារកខ្មែរ បានរងទុក្ខកម្មដោយខ្វាក់ភ្នែក ព្រោះកាលបើកើតមកឆ្មបខ្លះយកទឹកក្រូចឆ្មារប្រ

ចាប់ដាក់ក្អែក ឬចោលក្អែកទទេគ្មានបានប្រើថ្នាំ) ដៃជើង មានម្រាមលើស ខ្វះ ឬកំបុត គ្រឿងកេរ្តិ៍ខ្មាស ជាភេទប្រុសឬស្រីឬខ្ទើយ សម្លេងស្រែកឮឬខ្សាវៗ ដែលជាកញ្ចក់សំរាប់ឆ្លុះនូវគម្ភីររបស់ទារក មាត់ប្រមុះធម្មតា ឬមានបែកកញ្ចែតកញ្ចាត ។ ពិតមែនតែការសង្កេតនេះជាភារៈលើពេទ្យឬឆ្មប តែប្រជាជនគួរទុកសញ្ញានេះសំរាប់ជាទីពឹងផ្ទាល់ខ្លួនទៅចុះ ព្រោះបើទារកកើតមកភ្លាមមានរូបកាយខុសពីធម្មតាគួរសន្មតថាទារកបានទទួល នូវជម្ងឺតិកជីវិត ទារកខ្លះតែងតែរង់ចាំវាសនា វិលវល់ក្នុងរវាង១ថ្ងៃទៅ១៥ថ្ងៃ,ៗចំ-ពោះបញ្ហាផ្ចិតបើទារកត្រូវស្លាប់បាត់បង់ជីវិតដោយចងផ្ចិតមិនជាប់ឬដោយស្អក់ ព្រោះផ្ចិតមិនស្អាត ទោសត្រូវធ្លាក់លើខ្មោចម្ដាយបុណ្យម្ដាយដើម ដែលមានចិត្តប្រណែនមកកាច់ដណ្ដើមយកទៅវិញ ។

## ក) អនាម័យទូទៅ

នៅខែដំបូងជីវិតទារកត្រូវតស៊ូនឹងការត្រជាក់ក្ដៅនឹងជម្ងឺ ។ ទារកចិញ្ចឹមតាមអនាម័យតែងប្រកបនូវសុខភាពខ្ពង់ខ្ពស់, តែការចិញ្ចឹមត្រូវជំពាក់នឹងការខ្វះខ្វែង, ការយកចិត្តទុកដាក់ពីអ្នកចិញ្ចឹម, ពីធនធានរបស់គ្រួសារៗ ចំពោះរឿងអនាម័យនេះខ្ញុំចែកជាបួន ៖-

ខ ១- បន្ទប់សំរាប់ទារក

ខ ២- សម្លៀកបំពាក់

ខ ៣- ការដុះលាងសំអាតកាយ

ខ ៤- ចំណីអាហារ -

«អ្នកដែលមានការៈចិញ្ចឹមទារកត្រូវឲ្យមានសុខភាពផ្ទាល់ខ្លួនស្អាតបរិសុទ្ធ ចង់ឲ្យស្អាតល់ការៈរបស់ខ្លួនដ៏ពិតប្រាកដ ព្រោះអ្នកនោះឯងត្រូវទទួលភារខុសត្រូវចំពោះជីវិតទារកដែលខ្លួនត្រូវថែរក្សា» ។ កិច្ចការនេះជាបន្ទុករបស់ម្តាយតែមួយមុខ, ព្រោះគ្មានបុគ្គលណាមួយអាចជំនួសសេចក្តីស្នេហារបស់ម្តាយចំពោះទារកនោះបានឡើយ ។ ទុកជាម្តាយមានជម្ងឺរវល់ធ្វើការអ្វីដែលបណ្តាលឲ្យចិញ្ចឹមកូនមិនកើតក៏ដោយ, ម្តាយនៅតែមានកិច្ចនឹងត្រួតត្រានូវការថែទាំនោះជាការខានមិនបាន ។ ការស្អាតជាការៈរបស់ម្តាយឬមេដោះពិសេសបំផុតក្រចកត្រូវកាត់ខ្លី មិនត្រូវទុកក្រចកវែងសំរួចសំរាប់លំអ ព្រោះក្រចកវែងអាចមុតសាច់ទារកនឹងជាជម្រករបស់មេរោគគ្រប់យ៉ាង ។

# ១) បន្ទប់សំរាប់ទារក

លើកលែងតែធ្វើមិនកើត, ទារកត្រូវមានបន្ទប់មួយដោយខ្លួនតែឯង ៗ បន្ទប់នោះត្រូវធំទូលាយមានខ្យល់អាកាសចេញចូលផ្លាស់ប្តូរបាន ។ នៅក្នុងបន្ទប់មិនត្រូវដាក់វត្ថុប្រដេងប្រដាងគ្មានសណ្តាប់ធ្នាប់ ដូចជាក្យួរសំពត់អាវរាត់រាយ, ចោលក្រដាស ៗលៗ បន្ទប់ស្អាតគ្មានធូលី ត្រូវបោសជូតដោយប្រើបាវក្រណាត់ទទឹកដើម្បីកុំឲ្យធូលីវាហើរចូលភ្នែកច្រមុះទារក ។ កុំដុះរលាស់ក្រណាត់តាមបង្អួចបន្ទប់ដែលក្មេងដេក ព្រោះធូលីវាអាចហុយចូលមកក្នុងបន្ទប់ ។ គោងធ្វើគ្រែតូចមួយនឹងពូកសំរាប់ឲ្យទារកដេក ។ វាត្រូវដេកដោយខ្លួនតែឯង ៗ ហេតុផលមិនឲ្យទារកដេកជាមួយនឹងម្តាយឬអ្នកថែទាំនោះ ព្រោះខ្លាចមនុស្សធំបម្រះប្រែបុះឡើងប៉ះឬសង្កត់កូនក្មេងនឹងជាកិច្ចសំរាប់ទម្លាប់វាឲ្យហ៊ានដេកម្នាក់ឯង ៗ ពិសេសទៅទៀតខ្លាចក្រែងមានការឆ្លងជម្ងឺពីមនុស្សចាស់ ព្រោះមនុស្សចាស់ទោះបីមានរោគក៏ដោយ ជួនកាលអាចទប់ទល់នឹងជម្ងឺបានដោយអត្តពលមានកម្លាំង, ការឆ្លងនោះគឺឆ្លងដោយទឹកមាត់នៅពេលដែលមនុស្សចាស់ក្អកឬកណ្តាស ។ បន្ទប់ដេកនោះត្រូវធ្វើឆ្ងាយពីផ្ទះបាយដោយខ្លាចក្មេងវាឈ្ងុកផ្សែង, ឆ្ងាយពីផ្លូវ, ដើម្បីកុំឲ្យមានធូលីហើរចូលបន្ទប់នឹងសម្លេងអ៊ូអរដែលបណ្តាលឲ្យក្មេងវាដេកមិនបាន, បេះតែភ្ញាក់កន្ត្រាក់

ដៃជើង ៗ បញ្ហានេះប្រស្រ័យនឹងការរៀបចំផ្ទះសម្បែងនិងរបៀបរៀបចំក្រុង ព្រោះ ៖

ក) បើផ្ទះតូច កូនច្រើនបន្ទប់សំរាប់ទារក—
នោះមិនអាចធ្វើទៅបានទេ ។

២ បើផ្ទះនៅជាប់នឹងថ្នល់ ក្នុងទីផ្សារសេចក្ដីស្ងប់ស្ងៀម ក៏មិនអាចនឹងមានបាន ៗ យ៉ាងដូច្នេះ បញ្ហាបន្ទប់ទារកនេះជាបញ្ហាពិបាកនឹងដោះស្រាយជាទីបំផុត ព្រោះវាប្រស្រ័យនឹងធនធានរបស់វង្សត្រកូលនិងអារ្យធម៌របស់ស្រុកនោះផង ៗ

## ១ ២ –សំលៀកបំពាក់របស់ទារក

ទារកខ្ចីត្រជាក់ និងត្រូវការមានសេរីក្នុងការកំរើកដៃជើង, តែគេនឹងដឹងថាកាលបើទារកនៅអាយុតិចត្រូវដណ្ដប់វាឲ្យជិត ៗ ចំពោះរឿងសំលៀកបំពាក់នេះខ្ញុំសង្កេតឃើញថាទារកខ្មែរច្រើនទទួលនូវការ អត្ថខាត់ដោយ ច្រើនតែស្រោតរណាល ប្រឡាក់ដីស្រមុកសំពត់អាវខ្មៅក្ដុលជាប់ដីក្រខ្វក់ គួរឲ្យខ្លាច ព្រោះវាជាជម្រកមេរោគ ៗ ទារកខ្មែរជាភាគច្រើនៗតែគ្មានស្រោមជើង និងស្បែកជើង ទោះបីវាចេះដើរហើយក៏ដើរជើងទទេផ្ទាល់នឹងដីក្រខ្វក់ ការសង្កេតនេះបានជួបប្រទះ លើគ្រួសារអ្នកស្រែចំការនិងអ្នកមានធនធាន

ជាមធ្យម ដែលកើតទៅជាទម្លាប់តៗគ្នាមក ។ ខ្លួនប្រាណគ្មានអ្វីគ្របដណ្ដប់ ហើយជាបណ្ដោយធម្មជាតិឲ្យមកជះជាន់លើកាយតាមសេរី ។

បើមានសំពត់អាវវិញ តោងឲ្យស្អាតជានិច្ច ហើយគួរប្រើសំពត់អាវពណ៌ស ព្រោះងាយមើលឃើញការគ្រខ្វក់ ។ សំពត់ពណ៌អាចប្រើបានបើក្នុងនោះបេះដើរ ព្រោះពណ៌សជាលំអម្យ៉ាងដែរ ។ សំពត់ដែលប្រើនោះទៀតត្រូវប្រើតាមរដូវរងារឬក្ដៅ គឺពេលរងារត្រូវប្រើសំពត់ក្រាស ដូចជាសំពត់សំឡី ឬទេសឯកដែលមានរោមសត្វព័ទ្ធពីក្រៅ, ពេលក្ដៅត្រូវប្រើក្រណាត់ស្ដើង ដើម្បីមានប្រកឲ្យខ្យល់ប្ដូរចេញចូលតាមសំពត់ពីខាងក្រៅដងស្បែកបាន ។ កន្សែងដែលប្រើសំរាប់ជូតសំបោរក្ដី, សំរាប់រកដើម្បីត្រង់ទឹកមាត់ទារកក្ដី ត្រូវឲ្យស្អាតជានិច្ច ហើយត្រូវផ្លាស់ជាញយ ៗ ផង ។ យ៉ាងដូច្នេះក្នុងអត្ថបទនេះត្រូវយកការស្អាតជាការចាំបាច់នៃសំពត់ ត្រូវប្រើតាមវ័យទារកនឹងតាមរដូវ ។

## ១៣ ការដុះលាងសំអាតកាយ

ស្បែកជាកន្លែងសំរាប់បញ្ចេញញើស ក្នុងញើសមានគ្រឿងដែលធាតុក្នុងមិនត្រូវការ ហើយធាតុនោះត្រូវការបញ្ចេញចោលមកខាងក្រៅតាមរន្ធតូច ៗ របស់ស្បែក ។ ទឹកនោមនឹងលាមកតែងតែធ្វើឲ្យស្បែកទារកមិនស្អាត

កើតមាស់ ឬលោក, ព្រោះទារកនោមច្រើនដុះច្រើន, យ៉ាងដូច្នេះត្រូវសំ-
អាតស្បែកទារកកុំឲ្យរាលោក, ពិសេសបំផុតត្រូវសំអាតស្បែកត្រង់ទ្វារលាមក
ដែលដាក់ខ្នើយដែលយើងដូចទីងការលោកបណ្តាលឲ្យទារកយំ, ដេកមិន
សូវបាន ។

ពេលដែលត្រូវងូតទឹកទារកគឺពេលដែលផ្ចិតវាជ្រុះហើយ
ស្បែកវាស្អាតល្អ ។ មុនពេលនេះត្រូវតែជូតជូតខ្លួនប្រាណដោយទឹក
ក្តៅអុនៗនិងសាប៊ូ ។ ការរៀបចំផ្ចិតជាការចាំបាច់ព្រោះវាជាជីវិតរបស់
ទារក ។ ចំពោះទឹកដែលប្រើសំរាប់ងូតទឹកទារកជាបញ្ហាមួយដែលខ្ញុំ
ពិបាកនឹងដោះស្រាយ ព្រោះប្រជាជនពុំអាចមានទឹកម៉ាស៊ីនមកប្រើតាម
គោលបំណងនោះឡើយ តែដើម្បីកំចាត់មេរោគដែលអាចនៅក្នុងទឹកនោះ
យើងអាចយកទឹកទៅដាំឲ្យពុះហើយទុកឲ្យវានៅក្តៅអុនៗ ក៏បានដែរ ។
ចានដែកមួយធំដាក់ខ្នើយសំរាប់ដាក់ទារក ដើម្បីងូតទឹក ។ ក្បាលទារកត្រូវ
ចេញផុតពីទឹក ព្រោះខ្លាចវាឈ្ងុះទឹកនិងកុំឲ្យទឹកចូលត្រចៀកវាដែលជាហេតុ
បណ្តាលនាំឲ្យកើតអំពៅអំបែកហូរខ្ទុះ ។ ទារកខ្លះអកុសលមានទទួល
គ្រោះថ្នាក់ដល់ទៅថ្លង់បាន ព្រោះតែមិនប្រយ័ត្នទឹកចូលក្នុងត្រចៀកទារក
តែប៉ុណ្ណោះ ) អ្នកងូតទឹកយកដៃឆ្វេងទៅទ្រកញ្ចឹងកទារកឲ្យផុតពី ដៃស្តាំ

កាន់កន្សែងមួយស្អាត ឬក្រណាត់ពពុះទឹក (បារាំងហៅថាអេប៉ុង) ទៅជូតមុខ សក់ដៃជើងខ្លួនប្រាណដោយដុះសើៗ ៗ ត្រូវទុកទារកត្រាំទឹកចំនួន៥ ឬ១០នាទី ស្បែក រលាក្បាលគួរជូតឲ្យខ្លាំងបន្តិចដើម្បីកំចាត់ក្អែលក្រាស ដែលខាំជាប់នឹងស្បែករលាក្បាល ៗ ផុតទឹករួចភ្លាមត្រូវយកកន្សែងមកជូតខ្លួនប្រាណឲ្យស្ងួត, ព្រោះទារកឆាប់ត្រជាក់ណាស់ ៗ នៅពេលផុតទឹកម្តាយ ត្រូវសម្លឹងមើលរូបភាពកាយរបស់ទារក បើមានអ្វីប្លែកត្រូវនាំពត៌មានមកប្រាប់ពេទ្យ ៗ ប្រយ័ត្ននូវការលាកដោយប្រើទឹកក្តៅពេក កាលបើទារកមានជម្ងឺស្បែក ការផុតទឹកនោះត្រូវសម្រេចតាមការដឹកនាំរបស់ពេទ្យ ៗ ប្រមុះ ត្រចៀក ភ្នែក ត្រូវជូតដោយទឹកឆ្អិនស្អាតពិសេសទៅទៀត ដៃអ្នកផុតទឹកក៏នឹងក្រចកត្រូវឲ្យស្អាតដែរ ហើយកុំក្រចកទុកសម្រួចជាលំអ ព្រោះគ្រឿងលំអវាអាចមុតសាច់ទារកទឹងជាជម្រករបស់មេរោគ ៗ

## ១៤ – បំណើអាហារ

ការរបស់ស្ត្រីជាម្តាយត្រូវចិញ្ចឹមកូនដោយទឹកដោះខ្លួនឯង ព្រោះទឹកដោះម្តាយមានសេជាតិ (ខុជា) គ្រប់គ្រាន់ ៗ មិនតែប៉ុណ្ណោះវេជ្ជបណ្ឌិតតាមការពិសោធ បានឲ្យការថា នៅស្រុកណាដែលម្តាយចិញ្ចឹមកូនដោយទឹកដោះខ្លួនឯង ទារកស្លាប់មានចំនួនតិចស្តួចស្តើងណាស់

ហេតុនេះហើយ បានជានៅប្រទេសខ្លះ គេអនុញ្ញាតឲ្យម្ដាយយកកូនទៅទុកនៅកន្លែងដែលខ្លួនធ្វើការ ( ក្រសួងរាជការក្ដី, រោងចក្រក្ដី កន្លែងពាណិជ្ជកម្មក្ដី ) ដោយនៅកន្លែងនោះ គេបានរៀបចំកន្លែងសម្រាប់ទទួលមើលថែទាំកូននៅវេលាដែលម្ដាយកំពុងធ្វើការ តែដល់ពេលដែលត្រូវបំបៅកូន ម្ដាយមានសិទ្ធិនឹងមកបំបៅកូនតែរៀង ៗ ខ្លួន ៗ អង្គការនេះជាកិច្ចសំរាប់កុំឲ្យទារកស្លាប់មានកំរិតច្រើន ទីងដើម្បីជាការសម្រួលម្ដាយក្នុងការចិញ្ចឹមកូន ៗ

ទឹកដោះម្ដាយជាអាហារតែមួយមុខដែលក្រពះទារកអាចទទួលបានដោយគ្មានគ្រោះថ្នាក់, ព្រោះក្រពះងាយរំលាយអាហារ ។

ម្ដាយត្រូវបំបៅកូនប៉ុន្មានដងក្នុងមួយថ្ងៃ? មកទល់នឹងអាយុ ៤ខែ ទារកត្រូវបៅ ៧ ដង គឺ ៣ ម៉ោងម្ដង ។ ចាប់តាំងពីម៉ោង ៦ ព្រឹកទៅទល់នឹងម៉ោង ១២យប់ ។ ការសម្រាក ៦ ម៉ោង (គឺពីម៉ោង១២យប់ទៅម៉ោង៦ព្រឹក) ជាកិច្ចសំរាប់ឲ្យក្រពះទារកមានពេលបញ្ចេញអាហារចោល ទីងឲ្យម្ដាយមានពេលសំរាក ដើម្បីទុកឲ្យទឹកដោះចេញ ។ កន្លងពេលដែលទារកមានអាយុ ៤ខែមក, យើងអាចបំបៅកូនត្រឹមតែ ៦ដង ក្នុងមួយថ្ងៃ (ពីម៉ោង៧ព្រឹកទៅទល់ម៉ោង១០យប់) ។ ការប្រើកំរិតពេលបំបៅនោះជាទម្លាប់១អាចហុចផល

ល្អប្រសើរលើសុខភាពរបស់ទារក ។ ខ្ញុំបានប្រទះឃើញមាតាខ្លះខ្លះដោយស្រឡាញ់កូនពេកទៅ ឬ ដោយអាណិតព្រោះកូនយំ ក៏បំបៅកូនរាប់ដងមិនអស់, នេះជាហេតុមួយបណ្តាលឲ្យទារកហើមពោះ, លាមកដើរមិនទៀង ៗ បំពោះទារកយំនេះ ខ្ញុំសូមជូនយោបល់ថា: ទារកយំមិនមែនសុទ្ធតែឃ្លាននេះឡើយ, វាយំព្រោះវានោម ឬ ជុះមានសត្វអ្វីខាំ ! ក្អាក់ដោយសន្ទឹកថាសម្ងន់អ្វី១ ឬ មានសំពត់មកទ្រាប់មុខវាថប់ដង្ហើម, ការល្អទៅវិញកាលដែលវាយំទារកវាបានកំរើកដៃជើងខ្លួនប្រាណបណ្តាលឲ្យឆាប់បែកសាច់ ។ យ៉ាងដូច្នេះម្តាយគួរបណ្តោយឲ្យវាយំខ្លះផងទៅចុះ ដើម្បីជាសុខភាពរបស់វា ។ ពេលមុនដែលបំបៅម្តាយត្រូវជុះលាងដោះនឹងទឹកឆ្អិនឲ្យស្អាតហើយប្រយ័ត្នឲ្យប្រមុះទារក ផ្ទប់នឹងដោះខ្ទប់ក្រែងវាថប់ដង្ហើម, ពិសេសបំផុតនៅពេលយប់ជ្រៅណាមួយខ្ជិលណាក៏ជុំយដេកអស់កម្លាំងម្តាយច្រើនបំបៅកូនដោយបង្អៀងដេកម្តាយយុនដំណេកដេកលង់សន្លប់ខ្ទប់ច្រមុះទារកដែលជាហេតុបណ្តាលឲ្យទារកស្លាប់ដោយថប់ដង្ហើម ។

ការបំបៅត្រូវឲ្យបានកំរិតពេលនឹងបំបៅដោយដោះទាំងសងខាង ។ ឯម្តងពេលនោះ គេកំរិត១០នាទី ( គឺ៥នាទីដោះម្ខាងៗ ) តែអាចបន្ថយដល់ទៅ

១២ ឬ១៥នាទីបានកាលបើទឹកដោះវាចេញច្រើន គឺ ៦ទៅដល់៨នាទី ក្នុងដោះម្ខាងៗ ។

## ហេតុអ្វីខ្លះដែលបណ្ដាលឲ្យម្ដាយមិនបៅកូនដោយខ្លួនឯងបាន?

១ ) ដោយមិនបំបៅតែម្ដង ព្រោះចង់ស្រួលខ្លួន ខ្លាចខូចដោះឬបណ្ដាលមកអំពីការតូចចិត្ត ។

២ ) ដោយក្រវល់ តែប្រកបការងារ ខ្លះទៀតសុខចិត្ត ដើរទៅធ្វើមេដោះយកទឹកខ្លួននោះ ទៅបិញ្ចឹមទារកអ្នកដទៃទៅវិញ, សុខចិត្តឲ្យកូនរបស់ខ្លួនរងទុក្ខវេទនាគ្រប់យ៉ាង ឬយកកូនទៅឲ្យគេ ។

៣ ) ដោយមានជម្ងឺរបេង, ជម្ងឺបេះដូងឬដំបៅដោះជាដើម,, ចំពោះស្ត្រីដែលបំបៅកូនខ្លួនឯងនោះត្រូវជៀសវាងកុំខឹងកុំភ័យ, កុំតក់ស្លុតព្រួយ ព្រោះថាអាចធ្វើឲ្យទឹកដោះមិនល្អដែលបណ្ដាលឲ្យទារកមានជម្ងឺបាន ។

កាលបើម្ដាយបិញ្ចឹមកូនដោយទឹកដោះខ្លួនឯងមិនបានដោយឬដោយជម្ងឺ ដោយមានការៈអ្វី ១ - ទារកត្រូវរស់ដោយសារមេដោះ នឹងទឹកដោះ ឬម្សៅទឹកដោះគោ ។ តាមការសង្កេតរបស់ខ្ញុំ វិធីប្រើមេដោះនោះជាបញ្ហាពិបាកជាទីបំផុត ព្រោះស្ត្រីដែលមកស៊ីឈ្នួលជាមេដោះនោះ

ជាស្ត្រីចិត្តអាក្រក់ ហ៊ានផ្តាច់ទឹកដោះដែលសំរាប់កូនខ្លួនឯង ដើម្បីប្រយោជន៍ផ្ទាល់, ការដែលលះបង់កូនយកស៊ីឈ្នួលជាមេដោះនោះ យើងអាចស្មានថាស្ត្រីជាម្តាយ ប្រព្រឹត្តការរំលោភលើជីវិតរបស់ទារក, ចុះបើទារកដែលគ្មានទឹកដោះបៅហើយទៅជាឈឺៗរឺជាស្លាប់, អ្នកដែលធ្វើជាមេដោះមិនបានប្រព្រឹត្តបទឧក្រិដ្ឋសម្លាប់កូនខ្លួនទៅហើយ? ។

ចំណែកឯអ្នកប្រព្រឹត្តបទឧក្រិដ្ឋនោះគេអាចឆ្លើយថា ព្រោះក្រ ព្រោះជំពាក់បំណុលគេបានជាស៊ូបោះបង់កូនមកស៊ីឈ្នួលជាមេដោះ, ចម្លើយបែបនេះមិនសមជាជាមនុស្សធម៌សោះ គឺជាអ្នកបង្កើតកូនហាក់ដូចជាសត្វតិរច្ឆានអញ្ចឹងដែរ (គួរឲ្យពិចារណាណាស់!) ។ មេដោះទី២ គឺស្ត្រីដែលបានយកកូនទៅឲ្យយាយជី ឬ ឲ្យអ្នកដទៃទៀត, ព្រោះក្រ, ព្រោះគេផុតគ្មាន ។ ស្ត្រីទាំងពីរប្រភេទនេះ បើអ្នកតាមចរិកសាស្ត្រវិញ ឃើញថាជាមនុស្សខ្វះការមេត្តា ពិសេសបំផុតលើរូបកាយកូនរបស់ឯង, ចុះបើអ្នកដែលជួលមេដោះបែបនេះមកបំបៅកូនរបស់ខ្លួន, កូននោះវាមានចិត្តគំនិតបែបណាទៅវិញ ជាប់ទៅអនាគតកាល? ចំណែកឯអ្នកជួលវិញ ឃើញថាបានរួមដៃបមគំនិតជាមួយនឹងមេដោះដែលមានចិត្តគំនិតមិនបរិសុទ្ធ

ដែរ, នោះជាចេតនាក្តី មិនចេតនាក្តី ។ ជំពូកមួយទៀត គឺការចិញ្ចឹមកូនដោយទឹកដោះគោឬម្សៅទឹកដោះ។ ការចិញ្ចឹមកូនបែបនេះជាកិច្ចពិសេស គឺលុះត្រាតែម្តាយពុំអាចចិញ្ចឹមកូនដោយទឹកដោះខ្លួនឯងពិតប្រាកដមែន, ព្រោះម្តាយក្តី, អ្នកឈ្នួលបំបៅក្តី, ច្រើនតែមិនចេះក្បួនខ្នាត, ទុកបើចេះដឹងច្រើនតែមានការធ្វេសប្រហែស ទារកត្រូវឈឺ, រំខានចិត្តគំនិតពល់ពេលវេលា

ឧបសគ្គនៃការចិញ្ចឹមទារកដោយទឹកដោះម្សៅទឹកដោះគោ

ក) ពិបាករកម្សៅ ឬ ទឹកដោះគោ.

ខ) ការសំអាតគ្រឿងប្រដាប់ប្រដា

គ) ធ្វើការខ្ជះខ្ជាយដោយអស់កម្លាំង ងងុយដេកឬមិនស្រួលខ្លួន (មិនត្រូវម៉ោងពេល, បំបៅហួសកំរិត ដើម្បីកុំឲ្យទារកយំ)

ឃ) ពុំអាចដឹងថាម្សៅឬទឹកដោះនោះប្រើបានឬមិនបាន (ដោយហួសពេលដែលត្រូវប្រើ) ព្រោះអ្នកជំនួសគេមិនសូវគិតពីសុខភាពមិនសុខភាពនោះទេ ព្រោះបញ្ហាប្រាក់ជាបញ្ហាពាណិជ្ជកម្ម ។

តាមការសង្កេតខ្ញុំនឹកឆ្ងល់ថា មាតាខ្មែរសព្វថ្ងៃនេះបែបដើរលឿនបត្តិប មិនជាអ្នកមានឬក្រចូលចិត្តនិយមប្រើការចិញ្ចឹមកូនដោយម្សៅទឹកដោះ

គោនោះជាការច្រើន ។ ចំពោះអ្នកមានបំណាច់ឲ្យនេះងាយដោះស្រាយ ព្រោះគេមានប្រាក់ទិញ, មានឈ្នួល, ចុះឯអ្នកក្រវិញមានប្រាក់ឯណាទៅទិញ មេក្របុទឹកដោះគោ ហើយញ្ញែតែបីកូនត្រាក់ៗ ចុះទៀតរកសុំគេខាតពេលវេលាទីងប្រកបការងារផ្សេង ៗ មិនតែប៉ុណ្ណោះសោតខ្លួនដែលខ្វះការស្អាត មិនចេះក្បួនខ្នាត ទៅរកច្រើនតែទទួលនូវផលអក្រក់គ្រប់បែប ៗ ទារកឈឺស្គម ខ្លះទៀតត្រូវស្លាប់ ទុំវាស្មាទារកអកុសលដែលមានជម្ងឺវាមកផ្តាច់ជីវិត នៅពេលដែលអ្នកមានអាយុត្រឹមតែ៦ខែឬ១ឆ្នាំ ជីវិតអ្នកខ្លះម៉្លេះ ខ្ញុំទាល់តែគ្មានពេលទីងធ្វើការជូនទៅមាតុប្រទេសម្តងសោះ ។

កង់អត្ថបទ« អាហារនេះ » ខ្ញុំមិនហ៊ានបំបែកឲ្យល្អិតទៀយព្រោះប្រជាជនគាត់ច្រើនពុំអាចអនុវត្តបានទៀយ ព្រោះបញ្ហាប្រាក់ជាបញ្ហាសំរាប់អនុវត្ត ។

## ១៥ កម្មវិធីនៃជីវភាពទារក

«ស្មារតីទារកប្រាស្រ័យទីងការទម្លាប់» ។

### ក ដំណេក

អាយុមុនមួយខែ, ទារកត្រូវការដេកច្រើន, វាយំព្រោះឃ្លានឬផុះ

នោម ៗ ត្រូវបំបៅវាឲ្យត្រូវម៉ោង) ពេលគឺកំណត់៣ម៉ោងម្ដង (៨ដងក្នុង១ថ្ងៃ២៤ម៉ោង) នេះចំពោះទារកដែលកើតមកមានទម្ងន់ជាងបីគីឡូ ៗ បើទារកខ្សោយទម្ងន់តិចយើងអាចបំបៅ៧ដងក្នុងមួយ ហើយបន្ថយឲ្យតិចជាង៣ម៉ោងក្នុងម្ដងៗ ៗ ត្រូវផ្ដេកទារកដោយផ្អៀងម្ដងខាងស្ដាំម្ដងខាងឆ្វេង ដើម្បីកុំឲ្យវាក្អួ ៗ ទារកត្រូវដេកច្រើន តែពេលម៉ោងដេកនោះតោងបន្ថយ កាលបើទារកកើនអាយុ , ទុកជាយ៉ាងណាក៏ដោយពេលដេកត្រូវតែឲ្យលើសពេលដែលវាមិនដេកជានិច្ច ៗ ការទម្លាប់ឲ្យទារកបៅក្បាលដោះជាកំហុសមួយយ៉ាងធំ ព្រោះក្បាលដោះជាគ្រឿងសំរាប់នាំមេរោគនឹងបណ្ដាលឲ្យជម្ងឺមានខ្យល់ក្នុងពោះវៀន ៗ

ខ ) ការបញ្ចេញទារកមកក្រៅ - ទារកពុំអាចរស់នៅតែក្នុងបន្ទប់មួយតែមុខឡើយ បញ្ហានេះមានការស្មុគ្រស្មាញចំពោះគ្រួសារដែលដេកនៅក្នុងទីក្រុង ដោយពីបាករកខ្យល់អាកាសស្អាត ទើបត្រូវដឹកនាំទារកកាត់ផ្លូវដែលហុយសុទ្ធតែធូលី ផ្លូវដែលប្រកបសូរសន្ធឹកបណ្ដាលឲ្យទារកភ្ញាក់ផ្អើល ៗ ពន្លឺនឹងកំដៅព្រះអាទិត្យជាគ្រឿងសម្រាប់ការពារសុខភាពនៃទារក ៗ គ្រួសារអ្នកក្រត្រូវការបញ្ចេញទារកមកជាមួយខ្លួននៅក្នុងពេលដែលរកស៊ី តែវាសនាទារកត្រូវនៅក្នុងធុងទឹកកក កញ្ច្រែងត្រី ពន្ទាក់នឹង

ដែលនៅក្នុងចំណោមមនុស្សអ៊ូរអរប្រកបដោយអាកាសកខ្វក់ ទារកទុននេះរស់នៅដោយការផ្សងព្រេងសំណាង ព្រោះធម្មជាតិចេះតែមកបៀតបៀនលើសុខភាពជាអាចិន្ត្រៃយ៍ ។

## គ ) ការប្រយ័ត្ននឹងគ្រោះថ្នាក់

ទារកអាចចាប់យកគ្រាប់សណ្តែក គ្រាប់ទៀបដាក់បញ្ចូលទៅក្នុងរន្ធច្រមុះ ។ បើចូលទៅក្នុងមាត់វាអាចបណ្តាលឲ្យទារកថប់ស្លាប់បាន ។ ការធ្វេសប្រហែសនោះ វាអាចបណ្តាលឲ្យទារកទាញចាប់ប្រមូលម្ជុលខ្ទាស់ ឬម្ជុលដៃ លេបបញ្ចូលទៅក្នុងពោះ ។

នៅពេលដែលក្មេងចេះក្រឡាប់, វារ, លូន ត្រូវកុំដាក់វាចោលតែម្នាក់ឯងនៅលើគ្រែដែលគ្មានអ្វីឃាំង ព្រោះវាអាចរមៀលធ្លាក់បណ្តាលឲ្យស្លាប់ក៏សឹងបាន ។ នៅពេលដែលវាចេះដើរ ការប្រហែសនាំឲ្យក្មេងធ្លាក់តាមបង្អួច រលាកទឹកក្តៅ, រលាកភ្លើង យកគ្រឿងសំអាងមានថ្នាំសាបក្រូបកថ្នាំកក់សក់ទៅផឹកបណ្តាលឲ្យវាពុលស្លាប់បាន ។

-xxx-

# អត្តពលកម្ម

(តពីលេខ២)

អត្តពលកម្ម ធ្វើឲ្យមានបញ្ញាស្មារតី ឲ្យមានសីលធម៌ ឲ្យមានកម្លាំងកាយ កម្លាំងចិត្ត ។ លទ្ធផលទាំងបីនេះធ្វើឲ្យមានឧត្តមប្រយោជន៍ ដល់ខ្លួនឯង ដល់គ្រួសារ ដល់ជាតិ ដល់មនុស្សជាតិទូទៅ ។

ប្រយោជន៍ផ្ទាល់ខ្លួន .. កាលណាប្រាណមានសុខភាពស្រួល បញ្ញាស្មារតីក៏បានភ្លឺស្វាង ព្រោះអង្គទាំងប៉ុន្មានរួមគ្នាមក ដូចជាខួរក្បាល ជាដើម បង្កើតឲ្យបានជាប្រាណរូបមានជីវិត រូបបេះកំរើក ។

បើខួរក្បាលជាអង្គមួយ បេះដូងជាសាច់មួយ អង្គនេះនឹងសាច់ដុំនេះក៏វា បេះប្រែប្រួល ដូចសាច់ដុំធម្មតា គឺបេះធំ បេះរីក បេះលូតលាស់ ។

បេះដូងនឹងខួរក្បាលជាទីពុំនាក់អាស្រ័យ របស់បញ្ញានឹងសីលធម៌ ។

ទីកន្លែងនេះបានសុខស្រួលបើទីនេះធំទូលាយ បញ្ញាស្មារតីនឹងសីលធម៌ ក៏នឹងបានធំទូលាយដែរ ។ ប្រាណជាបណ្ដោលជាបង្អែកយ៉ាងមាំគឺជាគ្រឹះ សម្រាប់ទ្រទ្រង់ នូវបញ្ញាស្មារតីនឹងសីលធម៌ ។

ធ្វើឲ្យប្រាណបានលូតលាស់ស្រួល ឲ្យមាំមួនគឺធ្វើឲ្យបញ្ញាស្មារតីមាំមួន ឲ្យភ្លឺ ឲ្យវៀងវៃ ឲ្យឆ្លាត ។ កាលណាប្រាណមិនសុខ ខួរក្បាល ស្មារតីក៏មិនបានធម្មតា វាវិលវល់ រកតែគិតអ្វីៗក៏ពុំកើត វានាំបណ្ដាលទុក្ខ

មកផ្គុំគ្រប់ប្រេក គ្រប់ផ្លូវដែលជាទីខាន ដល់ការត្រិះរិះពិចារណា ។ កាលណាបញ្ញាល្អគួរលាស់ស្រួល ក៏ត្រូវតែពត់នឹងអប់រំ បញ្ញាស្មារតីនោះឲ្យបានជាប្រយោជន៍ដល់មនុស្សទូទៅ ដោយខំបាត់បញ្ញាខូចខិលពុករលួយរើសយកតែបញ្ញាកសាង បញ្ញាស្មារតីនឹងជាសីលធម៌ ក៏ទោទន់ទៅលើអំពើល្អពុំខាន ព្រោះអ្នកហាត់ តែងតែធ្វើសាប់ដុំឲ្យបានតាមបំណងផ្សេង ៗ ។

អ្នកធ្វើអត្តពលកម្មគ្មានបំណាយពេលឥតប្រយោជន៍ឡើយ គឺគេបែះបែកពេលសម្រាក់ប្រកបការបំពេញជីវិត សម្រាប់លំហែរកាយ រកការសប្បាយនឹងកីឡាគេជៀសវាងការសប្បាយដោយល្បែង ស្រា ស្រី នឹងល្បែងស៊ីសង ជក់ថ្នាំ ។

ដោយសារបុបំពោះមនុស្សម្នាក់ៗ អត្តពលកម្មធ្វើឲ្យរូបកាយបានសុខបញ្ញាស្មារតីល្អ សីលធម៌ល្អ ៗ លក្ខណៈសម្បត្តិទាំងបីនេះប្រសើរជាងរបស់អ្វីៗទាំងអស់ ។

ប្រយោជន៍ដល់ជាតិ មុននឹងនិយាយពីប្រយោជន៍ដល់ជាតិ នឹងមនុស្សជាតិ គោងរកផលដល់គ្រួសារជាមុន ព្រោះជាតិនឹងមនុស្សជាតិប្រស្រ័យទៅដោយគ្រួសារដែលជាផ្នែកនៃជាតិមានមនុស្សតិចៗ គ្រួសារណា

មាំមួនគឺជាគ្រួសារមានជោគជ័យ ព្រោះសង្គមមនុស្សដែលគង់នៅដល់សព្វថ្ងៃនេះ ជាពួកអ្នកមានរូបភាពក្លាហានមាំមួនពូកែដោយកម្លាំងខ្លួន ។ គឺអ្នកមាំមួននោះឯងកាលដើមឡើយ ទៅជាទីគោរពរបស់អ្នកទាំងពួង ហើយយូរៗទៅក៏ទៅជាអ្នកដឹកនាំ ព្រោះអ្នកនោះការពារគេបានក្នុងគ្រាក្រ ។

មនុស្សមាំមួននេះ បេះបំរើដល់គ្រួសារដល់ពួកមនុស្សបេះធ្វើឲ្យមានការរៀបរយក្នុងគ្រួសារតូច បន្ទាប់មកទៀត ទៅជាអ្នកការពារដល់មនុស្សជាតិ ។ គ្រួសារណាមិនឈឺចាប់ គ្រួសារនោះបានធ្វើការច្រើន ជីវភាពនិងសីលធម៌របស់គ្រួសារនោះក៏តែងតែបំរើនឡើង ព្រោះខ្លួនបានប្រកបការច្រើន ដោយកម្លាំងពលំ ។

ជាតិគឺជាកងមួយបេះតែឈានទៅមុខគ្មានថយមួយពេល កាលណាថយគឺស្លាប់គឺរលាយ ។ ជាតិដើរព្រោះសម្បូណ៌មនុស្សធ្វើការ ច្រើនលើសមនុស្សស្រម៉ាក ព្រោះបើមានមនុស្សស្រម៉ាកច្រើនក្នុងសង្គម សង្គមនោះមិនដើរដោយអ្នកដេកស៊ីច្រើនជាងអ្នកធ្វើការ ។

អត្តពលកម្មយ៉ាងហោចណាស់ ក៏បេះធ្វើឲ្យមនុស្សបេះរស់ខ្លួនឯង គឺមិនមែនរស់ដោយបញ្ញើគេ ។ អ្នកធាក់ស៊ីក្លូ អ្នកភ្ជួរស្រែរស់ដោយកម្លាំងខ្លួនបុគ្គលៗ គេឥតបានយកបញ្ញា ទៅធ្វើជាឧបករណ៍សម្រាប់រស់ឡើយ

សម្រាប់ធ្វើជំនួញលើកម្លាំងអ្នកដទៃទេ ។

កូនគោ កូនជ្រូក កូនមាន់កើតឡើងដូចជាពុំសូវមានខ្លិន មានគមខ្នង មានកំបុតជើង តើព្រោះអ្វី? ព្រោះវារស់នៅសម្រេចតាមធម្មជាតិច្រើន វារស់នៅដោយអាកាសល្អ ដោយអាហារមានជាតិ ព្រោះធម្មជាតិខ្លះក៏អាចឲ្យផលដល់មនុស្សទីងសត្វណាស់ដែរ ។ ឯកូនមនុស្សវិញច្រើនកើតមកខ្វិន គមខ្នង ខ្វាក់ថ្លង់ ជាប់ជម្ងឺផ្សេង ៗ ច្រើននេះ ពីព្រោះតែសង្គមពុករលួយ វាឲ្យទោសទុក្ខដោយខ្វះអាហារ ខ្វះផ្ទះ ខ្វះអនាម័យ ខ្វះទឹក ខ្វះការកំរើកដោយសេរី ដោយភូមិតូចមានមនុស្សច្រើន ដោយទីក្រុងក្រខ្វក់គ្មានសួនច្បារ ទីងទីលានកីឡា ឲ្យមនុស្សដកដង្ហើមស្រួល ។ ដោយសេចក្ដីសប្បាយអ្នកអស់នោះមានតែស្រា ស្រី ល្បែងពាលា ដែលជាវត្ថុសម្រាប់ឲ្យស្មារតីមនុស្សដេកត្រាំក្នុងការក្រខ្វក់ ដេកត្រាំតាមសំណាង ដេកត្រាំនៅចាំទេវតាមកជួយ ដោយយកតែជំនឿក្រខ្វក់ ៗ មកបំពេរត្រចៀក ដូចជាត្រូវសព្ទ របស់ការលោមក ។

សង្គមសម្បូណ៌មនុស្សធ្វើការ គឺមនុស្សស្រឡាញ់អត្តពលកម្មនឹងកីឡា ។

ដើម្បីឲ្យបានមនុស្សធ្វើការច្រើន គោងតែមនុស្សសុខ ហើយមាំផង ។

ក្រុងណា ខេត្តណា មានមនុស្សធ្វើការហើយអត់ទីសំរាក អត់ទីលានកីឡា ឥតមនុស្សលេងល្បែងកីឡា ក្រុងនោះ ខេត្តនោះ សម្បូណ៌តែមនុស្សរីងរៃ និងជម្ងឺផ្សេងៗ ។ ដើម្បីបំបាត់នូវកាកនិងសំណល់មនុស្ស កាលផុតពីចម្បាំងលើកទី២រួចហើយ ប្រទេសអឺរ៉ុបខំយ៉ាងខ្លាំង បង្កើតបង្កើនសាលាអនុវិទ្យាល័យ និងសាលាទីសាបាមោក្ខ បើកឲ្យមានការសិក្សាជ្រៅៗ និងដឹកនាំយុវជន ប្រជាជន ឲ្យលះបង់ស្រាស្រីដែលជាថ្នាំពុលយុវជន ឲ្យកាប់សម្លាប់គ្នាគ្មានញញើតដៃ ដើម្បីឲ្យរួចសតិសម្បជញ្ញៈ និងកែរូបរាងកាយពុករលួយចេញ ។

ដូចនោះអត្តពលកម្មនិងកីឡាអាចធ្វើឲ្យមនុស្សមានកម្លាំងកាយល្អ ប្រកបការងារដោយសុខសាន្ត សីលធម៌ប្រសើរ ជាការជួយស្វែងរកសាមគ្គីភាពរវាងមនុស្សនិងមនុស្ស និងបណ្តុះសតិសម្បជញ្ញៈឲ្យបានល្អ ។

---

ទំនាយហោរ

– ក្នុងរយៈដប់ឆ្នាំទៅមុខ អ្នកឯងនឹងបុះក្រហើយអភ័ពទៀតផង

– ចុះ ដល់ផុតពីដប់ឆ្នាំនោះទៅ វាយ៉ាងម៉េច ?

– ដល់ទៅពេលនោះមុខជាធូរទៅវិញ ព្រោះអ្នកឯងនឹងធ្លាប់ខ្លួនទ្រាំទៀតបេះតែបាន ។

# កំណាព្យខ្មែរ

## ភស្នាសិស្សខ្មែរ

សិស្សខ្មែរច្រើនគ្នាកំព្រាពេក ព្រោះមានតំរេកត្រេកវិជ្ជា
ព្រាត់ពីភូមិឋានប្រាណគ្មានគ្នា មានតែវិហារជាតំនាក់ ។
រស់នៅសព្វថ្ងៃទីងព្រះសង្ឃ លោកជួយស្រោចស្រង់ជាបាយប្រាក់
តិចតួចស្តួចស្តើងលោកមិនលាក់ ចំជួយទុកដាក់ដូចបិតា ។
បាយទឹកត្រីកល្វាបនាបតាមមាន ស៊ីអត់ស៊ីឃ្លានគ្មានអាហារ
អំបិលប្រហុកទុកដូចផា បំអែតអាត្មាលេបទាំងប្រឹង ។
ស៊ីណាស់ឃ្លានណាស់រហ័សចង់ ពមបាយកត្រង់ចង់ទាំងខឹង
សំរក់ទឹកភ្នែកទឹកដណ្តឹង នឹកម្តាយតើដឹងកូនដែរឬ ? ។
កម្លាំងរកគ្មានឃ្លានចង់បេះ កង់ទ្រូងស្ទើរប្រេះផេះទួលលើ
ម្តាយអើយអ្នកម្តាយកូននេះគឺ គេងគ្មានពន្លឺឈឺក្រៃក្រៃ ។
ពេលយប់ព្រលប់ចំស្វាធ្យាយន៍ មិនធ្វើរាយមាយចំត្រជរ

ខន្តីញ៉ាមរៀនវេយ្យាករណ៍   មួសពេមឈ្មួតក៏មិនឈប់ ។
បើកក្អែកហែកខ្ទួរស្ទួរសេរសេរ   គិតគ្គួរគ្នូតគ្នេររេកគ្រប់
បង្គៀនប្រេនកាតផ្សែនបុយទ្រូប់   ជុយសោកពោកឈ្ងប់ទើបឈប់ការ
ស្ទួគ្ររៀនពល់ថ្ងៃក្រខំប្រឹង   មិនខ្ជិលមិនខឹងនឹងអាចារ្យ
ខំស្តាប់ខំត្រាប់ពាក្យលោកថា   ចិត្តចង់ប្រាថ្នាខ្ញុំឯកក្សហាន ។
ប្រាថ្នារហូតរបូតចប់   ចិត្តចង់មិនស្ងប់រាប់មិនបាន
តែអកុសលផ្តល់រំខាន   តាមផ្ទួលតាមប្រានឈានមិនដល់ ។
នេះព្រោះតែជាតិជាក្រក្រ   ទឹងខំត្រដរក៏ជាប់ខ្សល់
ខំណាស់ខាតណាស់រនែងឥតផល   ម្លោះហើយរកកលឈាសាលា ។
លាសោតក៏លាទាំងក្រៀមក្រស់   ចិត្តនៅអាលោះអស់អាចារ្យ
អាល័យមិនឃើញមិត្តស្នេហា   ខានឃើញជើងម៉ាក្តារសរសេរ ។
បេញផុតសោតទៀតក៏ពិបាក   ព្រួយចិត្តគ្មានស្រាកគ្មានទំនេរ
ព្រួយព្រឺឈឺប្រាណព្រោះមានគេ   ស្រែកខមថាទេមិនមើលមុខ ។
ល្ហើយចុះលោកអើយសិស្សសូមលា ទៅរកការងារនាស្រុកស្រែ
រកស៊ីជួយញាតិជាតិជាខ្មែរ   សិស្សខ្ញុំសុំតែឲ្យខ្មែរសុខ ។

(ឆិ. រី)

# លទ្ធផលនៃការសិក្សា

តារាងខាងក្រោមនេះបង្ហាញលទ្ធផលនៃការសិក្សានៅប្រទេសយើងក្នុងរយៈពីរឆ្នាំ

( ១៩៥៤–៥៥ និង ១៩៥៥–៥៦ )

| សញ្ញាបត្រ | ឆ្នាំសិក្សា | ចំនួនសិស្សប្រឡង | ចំនួនសិស្សប្រឡងជាប់ | ចំនួនសិស្សប្រឡងជាប់ក្នុងភាគរយ |
|---|---|---|---|---|
| មធ្យមសិក្សាបត្រទី១ | ១៩៥៣ ៥៤ | ៦៥ | ៣៧ | ៥៦ % |
| មធ្យមសិក្សាបត្រទី២ | -ដ- | ១៤៤ | ៦១ | ៤៣ % |
| សញ្ញាបត្រ (ឌីប្លូម) | -ដ- | ៦០៧ | ១៣២ | ២១ % |
| វិញ្ញាបនបត្រ | -ដ- | ៨៦៧២ | ៣២៤៥ | ៣៧ % |
| មធ្យមសិក្សាបត្រទី២ | ១៩៥៥-៥៦ | ៨០ | ៣២ | ៤០ % |
| មធ្យមសិក្សាបត្រទី១ | -ដ- | ១៧២ | ៦៦ | ៣០,៨ % |
| សញ្ញាបត្រ (ឌីប្លូម) | -ដ- | ៧៣៤ | ២៩៩ | ៤០,៧ % |
| វិញ្ញាបនបត្រ | -ដ- | ១២៩២៧ | ៧១៤៦ | ៥៦ % |

# មិនគ្រប់ជួបគ្នា

អាយួយ បានទិញស្បែកជើងពីរគូ លឿងនិងខ្មៅ ៗ អ្នកលក់ប្រុង ដាក់ទៅក្នុងប្រអប់មួយ ៗ ស្បែកជើងខ្មៅមួយនិងលឿងមួយ ៗ

ថ្ងៃក្រោយវាយកស្បែកជើងចេញពីប្រអប់នោះមកពាក់ហើយដើរលេង ផ្សារជួបនឹងពួកម៉ាកវាអាយង់ ៗ ឆ្ងល់សួរថា «ឯងឆ្កួតឬ? ឯងចង់ឲ្យគេសើចពេញទាំងស្រុក» –

អាយួយឆ្លើយថា «កុំសើចកុំយំ-អញដឹងថាវាល្ងើយបន្តិចហើយ តែឲ្យធ្វើយ៉ាងម៉េច បើអញទិញហួសទៅហើយ ម៉្យាងទៀតគួរឲ្យអញតែស្តាយទៀត ព្រោះអញនៅមានមួយគូរទៀតពណ៌ខុសគ្នាដូចអានេះអញ្ចឹង.

– បើយ៉ាងហ្នឹងម៉េចក៏អាមិនយកទៅដូរឯផ្ទះអ្នកលក់ស្បែកជើងវិញទៅ. (អាយង់ឆ្លើយ)

– ដូរម៉េចនឹងកើត បើវាដាក់ប្រកាសថា ឥវ៉ាន់ណាទិញហើយ មិនឲ្យដូរវិញទេ ៗ

---

«ការសិក្សាជាសោ សម្រាប់បើកទ្វារជនទាំងពួង» ។

«គេអាចបេះផលដំណាំបាន បើគេបានសាបព្រួស» ។

«ផលអ្វី ៗ ទាំងអស់ កើតមកពីហេតុ» ។

# សំនួរកំសាន្ត

មិត្តអ្នកអាន !

មិត្តអាចនឹងឆ្លើយសំនួរខាងក្រោមនេះបានឬទេ?

(សូមផ្ទៀងចម្លើយរបស់មិត្តនៅទំព័របន្ទាប់)

១- អ្នកណារកឃើញវិទ្យុសកម្មនៃរ៉ាឌិញ៉ូមមុនគេបង្អស់ ពីឆ្នាំណា ?

២- ចំនួនមនុស្សនៅក្នុងសាកលលោកទាំងមូលមានប៉ុន្មាន ?

៣- គេនាំម្រេចមកដាំនៅស្រុកខ្មែរពីឆ្នាំណា ? នៅខែត្រណា ?

៤- តើប៉ុន្មានឆ្នាំក្រោយពីពេលដាំ ទើបម្រេចឲ្យផ្លែ ?

៥- ដើមកៅស៊ូកើតមាននៅស្រុកខ្មែរពីឆ្នាំណា ?

៦- ដាំប៉ុន្មានឆ្នាំ ទើបកៅស៊ូឲ្យជ័រ ?

៧- កៅប៊ិហ៊ីនហើយ ឬ ដែលគេយកទៅក្រាលថ្នល់ ?

## បម្លើយសំនួរ

ដ្បិតយើងបានដឹងហើយថា អៀរ៉ានិញ៉ូមជាលោហធាតុមួយសម្រាប់យកទៅផ្សំធ្វើថាមពលបរមាណូ (energie atomique) ។ លោកប៊ិកកេរែល (Becquerel) បានរកឃើញវិទ្យុសកម្មនៅឆ្នាំ ១៨៩៦ ។ ពីរឆ្នាំក្រោយ គឺក្នុងឆ្នាំ ១៨៩៨ ពីយែរ និងម៉ារីគុយរី (Pierre et Marie curie) បានបន្តការពិសោធន៍នោះទៀតដោយបានចំរាញ់យករ៉ាដ្យូម (Radium) ពីស៊ិលអៀរ៉ានិញ៉ូម (Sel uranium)

លំដាប់មកទៀត លោករ៉ូថេរហ្វ័រ (Rutherford) ក៏បានរកឃើញការផ្លាស់ប្តូរនៃវិទ្យុសកម្មតាមការពិសោធន៍ហើយលោកហ្វែរមី (fermi) បានសង់ពិលបរមាណូ (Pile atomique) មុនគេបង្អស់នៅស៊ីកាហ្គោ ។

២- មនុស្សនៅសាកលលោក មានចំនួន ពីរពាន់ប្រាំរយប្រាំមួយលាននាក់ (២.៥០៦.០០០.០០០) ។

៣ - គេនាំម្រេចមកដាំស្រុកខ្មែរនៅឆ្នាំ១៨៦៩ ម្តងនៅ ១៨៩០ម្តង នៅខេត្តកំពត ម្រេចដុះនៅលើដីរេក្ខិននៅលើដីដែលទើបនឹងកាប់ព្រៃអស់ ។

ម្រេចដុះល្អតែនៅលើដីណាដែលមានដីរ«ស្លឹកឈើ»។

៤– ម្រេចផ្លែនៅឆ្នាំទីប្រាំពីរពីឆ្នាំដាំ។ដើម្បីទឹងឲ្យបានផលល្អ គេត្រូវថែទាំម៉ត់ចត់ណាស់ ហួសពីដំណាំបន្លែធម្មតាទៅទៀត ។

គេនាំម្រេចទៅលក់នៅប្រទេសក្រៅបាន ឯតម្លៃទឹងឡើងចុះ តាមផ្សារសាកលលោក ។ ក្នុងមួយឆ្នាំចំការកំពតឲ្យផលចំនួន ៤-០០០តោន

៥– កៅស៊ូមានដុះនៅស្រុកខ្មែរពីឆ្នាំ១៩២១ មានកំណើតនៅស្រុកប្រេសិល ។

៦– ក្រោយពីដាំប្រាំបីឆ្នាំ ទើបកៅស៊ូឲ្យជ័រ ហើយឲ្យផលចំនួន៣០-០០០តោនក្នុង១ឆ្នាំ កៅស៊ូ១គីឡូ ថ្លៃ៤២រៀល ។

៧– ពុំមែនទេ « កៅស៊ូ » ក្រាលថ្នល់ជាកាកប្រេងសាំងដែលហៅថា គូដ្រុង( goudron ) ក៏ប៉ុន្តែដោយវត្ថុនេះមានសភាពយឺតទាញបានដូចគ្នា ទើបគេប្រឡំយ៉ាងដូច្នោះ ។

( ចប់ )

ឃុទពាណិជ្ជ
ផ្ទះលេខ ១៣៥ មហាវិថី [illegible] ភ្នំពេញ

តម្លៃ១០រៀល